00652147

E58/1

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 16 / 03 / 2011
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត: សាធារណៈ / Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបញ្ញត្តិរបស់ អៀង សារី**
**ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារកំហុសផ្នែកនីតិវិធី**

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | **ចម្លងជូន:** |
|---|---|---|
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះសាលាដំបូង: | ជនជាប់ចោទ: |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | អៀង សារី |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | |
| | ចៅក្រម យ៉ា សុខន | មេធាវីការពារក្តីជនជាប់ចោទ: |
| សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី: | ចៅក្រមJean-Marc LAVERGNE | លោក អាង ឧត្តម |
| ពេជ អង្គ | ចៅក្រម ធូ មណី | លោក Michael G.KARNAVAS |
| Elisabeth SIMONNEAU FORT | | |

## I. សេចក្តីផ្តើម

១. នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ អៀង សារី តាមរយៈមេធាវីការពារក្តីរបស់ខ្លួន ("មេធាវីការពារក្តី") បានដាក់ញត្តិស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារកំហុសផ្នែកនីតិវិធី[1] ("ញត្តិស្នើសុំលុបចោល") ជាភាសាអង់គ្លេស ដោយមានភាសាខ្មែរដាក់នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១។មេធាវីការពារក្តីលើកឡើងចោទថាផ្នែកខ្លះនៃដីកាដំណោះស្រាយ[2]មានកំហុសផ្នែកនីតិវិធី ហើយស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងលុបចោលផ្នែកខ្លះទាំងនោះចេញពីដីកាដំណោះស្រាយ សម្រាប់មូលហេតុទាំងឡាយដូចបានរៀបរាប់ខាងក្រោមសហព្រះរាជអាជ្ញាសូមស្នើសុំឱ្យបដិសេធញត្តិស្នើសុំលុបចោលនោះដោយសារមិនអាចទទួលយកបានហើយជាការឆ្លាស់គ្នា បើសិនជាទទួលយកក៏ត្រូវបដិសេធចោលដែរ ដោយសារអង្គសេចក្តីរបស់វា។

២. តាមអង្គសេចក្តីនៃញត្តិស្នើសុំលុបចោលនោះ មេធាវីការពារក្តីលើកសំអាងថាដីកាដំណោះស្រាយមានផ្ទុកទៅដោយកំហុសជាក់លាក់មួយចំនួន ជាពិសេសទាក់ទងទៅនឹងភាគច្រើននៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ហើយគ្រប់ទម្រង់ទាំងអស់នៃការទទួលខុសត្រូវដែលបានចោទប្រកាន់[3]។ ពួកគាត់លើកសំអាងថា ឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវទាំងនេះមិនមានអង្គហេតុជាក់លាក់គ្រប់គ្រាន់ដើម្បីគាំទ្រដល់ការចោទប្រកាន់, ឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវ គឺត្រូវបានដាក់ចរិតលក្ខណៈខុស, ទម្រង់នៃការទទួលខុសត្រូវដែលឆ្លាស់គ្នាមិនគួរត្រូវបានឆ្លើយតបទេ, ការទាញសេចក្តីសន្និដ្ឋានគាំទ្រដល់អង្គហេតុសំខាន់ៗនៃឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវមិនត្រូវបានធ្វើឡើងតាមបមាណីយដ៏ត្រឹមត្រូវ ហើយផ្នែកនានានៃដីកាដំណោះស្រាយហួសផុតពីយុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេត។ ជាទូទៅ សេចក្តីអះអាងទាំងនេះគួរតែត្រូវបានបដិសេធចោល ដោយសារវាមានមូលដ្ឋាននៅលើ៖ ទី១) ការបកស្រាយខុសពីការរកឃើញអង្គហេតុក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ, ទី២) ការបកស្រាយខុសពីអង្គច្បាប់ពាក់ព័ន្ធ ទាក់ទងនឹងដីកាដំណោះស្រាយ, និងទី៣) ការវាយតម្លៃដោយបែបជ្រើសរើស និងដោយអន្លើៗទៅលើការរកឃើញអង្គហេតុដែលមាននៅក្នុងដីកាដំណោះស្រាយ។

## II. ញត្តិនេះមិនអាចទទួលយកបានទេ

៣. ញត្តិស្នើសុំលុបចោលនេះគឺមិនអាចទទួលយកបានទេ ដោយសារវិធានផ្ទៃក្នុងសម្រាប់ អវតក មិនអនុញ្ញាតឱ្យមានញត្តិស្នើសុំលុបចោល ឬធ្វើវិសោធនកម្មលើផ្នែកខ្លះនៃដីកាដំណោះស្រាយនៅពេលដែលវាចូលជាស្ថាពរហើយនោះទេ។ ការជំទាស់ទៅនឹងដីកាដំណោះស្រាយ អាចត្រូវបានធ្វើឡើង

---

[1] ឯកសារលេខ **E58**, "ញត្តិរបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារកំហុសផ្នែកនីតិវិធី", ថ្ងៃទី២៤ មករា ២០១១, ERN 00647801-7815 ["ញត្តិស្នើសុំលុបចោល"] ។

[2] ឯកសារលេខ **D427**, "ដីកាដំណោះស្រាយ", ថ្ងៃទី១៥ កញ្ញា ២០១០, ERN 00604508-5246 ["ដីកាដំណោះស្រាយ"] ។

[3] ញត្តិស្នើសុំលុបចោល, ទំព័រទី១ ។

ដោយមេធាវីការពារក្ដីតាមរយៈបណ្ដឹងឧទ្ធរណ៍មួយជូនទៅអង្គបុរេជំនុំជម្រះ ដោយអនុលោមតាមវិធាន៧៤.៣ ឬនៅក្រោយពេលដីកាដំណោះស្រាយចូលជាស្ថាពរ តាមរយៈអញ្ញត្រកម្មបឋមនានាជូនទៅអង្គជំនុំជម្រះសាលាដំបូង ដោយអនុលោមតាមវិធាន៨៩។ អញ្ញត្រកម្មបឋមមួយអាចត្រូវបានលើកឡើងតែកាលណាវាទាក់ទងទៅនឹង៖ ក) យុត្តាធិការរបស់អង្គជំនុំជម្រះ, ខ) ការរលត់បណ្ដឹងអាជ្ញា និង គ) មោឃភាពនីតិវិធីដែលត្រូវបានធ្វើបន្ទាប់ពីមានដីកាដំណោះស្រាយ[4]។

៤. ដោយហេតុថា មេធាវីការពារក្ដីបានដាក់បញ្ជីស្ថាពររបស់ខ្លួនស្ដីពីអញ្ញត្រកម្មបឋមទៅនឹងដីកាដំណោះស្រាយដែលមានចំណងជើងថា៖ " សេចក្ដីសង្ខេបអញ្ញត្រកម្មតាមវិធាន៨៩ របស់លោក អៀង សារី និងការជូនដំណឹងនៃការមិនគោរពតាមអនុស្សរណៈក្រៅផ្លូវការនានានាពេលអនាគតដែលត្រូវបានចេញជំនួសឱ្យសេចក្ដីសម្រេចមានសំអាងហេតុរបស់តុលាការ ដែលជាកម្មវត្ថុបណ្ដឹងឧទ្ធរណ៍" ("ញត្តិស្ដីពីអញ្ញត្រកម្មបឋម") នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ ហើយញត្តិស្នើសុំលុបចោលនេះ មិនបានអះអាងថា ជាអញ្ញត្រកម្មបឋមមួយទេ ដែលវាត្រូវបានស្នើសុំថាឱ្យបដិសេធញត្តិស្នើសុំលុបចោលនេះ។ ទោះបីជាវិធាន៩៨.២ អនុញ្ញាតឱ្យអង្គជំនុំជម្រះអាចផ្លាស់ប្ដូរការកំណត់បទចោទតាមរយៈសេចក្ដីសម្រេចរបស់ខ្លួនក៏ដោយ ក៏មិនបានអនុញ្ញាតឱ្យមានការធ្វើវិសោធនកម្មតាមរយៈការបន្ថែម ឬការដកចេញ ឬ"ការលុបចោល" អង្គហេតុនានាដែលមាននៅក្នុងដីកាដំណោះស្រាយនោះទេ "សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណាដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ..."។ ជាការផ្ទាស់គ្នា បើអង្គជំនុំជម្រះសាលាដំបូងរកឃើញថា ញត្តិស្នើសុំឱ្យលុបចោលនេះ អាចទទួលយកបានវិញនោះ សហព្រះរាជអាជ្ញាជូនសេចក្ដីសន្និដ្ឋានថា វាគួរតែត្រូវបានបដិសេធចោលដោយសារអង្គសេចក្ដីរបស់វា។

## III. អំពីច្បាប់

### ក. សុពលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ

*ធាតុផ្សំសំខាន់ៗ*

៥. នៅក្រោមវិធាន៦៧.២ ដីកាបញ្ជូនរឿងទៅជំនុំជម្រះមួយដែលមានសុពលភាព បើវាមានធាតុផ្សំសំខាន់ៗដូចតទៅនេះ៖ ទី១) "អត្តសញ្ញាណនៃជនជាប់ចោទ", ទី២) "ការបង្ហាញអំពីអង្គហេតុ", និងទី៣) "ការកំណត់ប្រភេទបទល្មើស" នៃអង្គហេតុបែបដូច្នោះ ។ វិធាន៦៧.៣.គ បង្កប់ន័យថា សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាដំណោះស្រាយមួយកាលណាមាន *inter alia* "ភស្តុតាងគ្រប់គ្រាន់" ប្រឆាំងនឹងជនត្រូវចោទនោះ។

[4] វិធាន៨៩ នៃវិធានផ្ទៃក្នុង ។

*ភាពគ្រប់គ្រាន់នៃភាពជាក់លាក់នានា*

៦. អង្គហេតុសំខាន់ៗត្រូវបានគេផ្តល់និយមន័យថា ជាអង្គហេតុមួយដែលសាលក្រមត្រូវពឹងផ្អែកលើជាសំខាន់យ៉ាងខ្លាំង[5] ។ អាស្រ័យហេតុដូច្នេះ វាជាការចាំបាច់ "ដើម្បីធ្វើសេចក្តីថ្លែងសំអាងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះពីអង្គហេតុសំខាន់ៗដែលគាំទ្រដល់ការចោទប្រកាន់នានា"[6]។ ភស្តុតាងដែលគាំទ្រអង្គហេតុសំខាន់ៗទាំងនោះ មិនត្រូវបានលើកថ្លែងសំអាងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ ប៉ុន្តែគេប្រើប្រាស់ភស្តុតាងទាំងនោះដើម្បីបង្ហាញសក្ខីកម្មពីអង្គហេតុនៅពេលសវនាការ[7] ការរៀបរាប់ពីអង្គហេតុសំខាន់ៗនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមួយត្រូវតែមានភាពជាក់លាក់ "ដើម្បីប្រាប់ជាព័ត៌មានដល់ចុងចោទឱ្យបានច្បាស់លាស់អំពីចរិតលក្ខណៈ និងមូលហេតុនៃបទចោទនានាប្រឆាំងនឹងគាត់[8] ដើម្បីឱ្យគាត់អាចត្រៀមរៀបចំនូវការការពារក្តីមួយដ៏មានប្រសិទ្ធភាព និងប្រសិទ្ធផលបាន[9]"។ គោលបំណងបឋមនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្រៅពីការផ្តល់នូវមូលដ្ឋាននៃករណីរឿងនោះនៅចំពោះមុខតុលាការ គឺការផ្តល់ដល់ជនជាប់ចោទនូវការជូនដំណឹងយ៉ាងគ្រប់គ្រាន់ពីករណីរឿងប្រឆាំងនឹងគាត់ ដោយអនុលោមទៅតាមសិទ្ធិនានារបស់គាត់ដែលមាននៅក្រោមមាត្រា ១៤.៣ នៃ ICCPR។

៧. ប្រការជាក់លាក់យ៉ាងគ្រប់គ្រាន់នៃអង្គហេតុសំខាន់ៗ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានកំណត់ដោយ៖ (i) ចរិតលក្ខណៈនៃការលើកឡើងចោទប្រកាន់, (ii) ចរិតលក្ខណៈនៃឧក្រិដ្ឋកម្មជាក់លាក់ដែលបានចោទប្រកាន់, (iii) វិសាលភាព ឬទំហំដែលអំពើ ឬព្រឹត្តិការណ៍នានាដែលត្រូវបានលើកឡើងចោទប្រកាន់បានកើតឡើង, (iv) កាលៈទេសៈនានាដែលនៅក្រោមឧក្រិដ្ឋកម្មទាំង

---

[5] *រដ្ឋអាជ្ញា ទល់នឹង Kupreškić និងគូកន,* សំណុំរឿងលេខ IT-95-16-A, សេចក្តីសម្រេច, ថ្ងៃទី២៣ តុលា ២០០១, កថាខណ្ឌទី ៨៩ ។

[6] ឯកសារលេខ **D97/14/15,** សាធារណៈ, សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម (JCE), ថ្ងៃទី២០ ឧសភា ២០១០, ERN00486521-00486589 ត្រង់កថាខណ្ឌទី ៣២ (*ដោយបានស្រង់សម្តី* inter alia, *រដ្ឋអាជ្ញា ទល់នឹង* Kupreškić, *ដូចមុនដដែល*, ត្រង់កថាខណ្ឌទី ៨៨) ។

[7] *រដ្ឋអាជ្ញា ទល់នឹង* Norman, សំណុំរឿងលេខ SCSL-04-14-T, សេចក្តីសម្រេចលើញត្តិទីមួយរបស់ជនជាប់ចោទសម្រាប់សេវា និងការ នាំខ្លួនមកឆ្លើយចំពោះមុខតុលាការ នៅលើដីកាបញ្ជូនរឿងរួមទៅជំនុំជម្រះ, ថ្ងៃទី២៩ វិច្ឆិកា ២០០៤, កថាខណ្ឌទី២៤ ។ *សូមមើលផងដែរ,* ឯកសារលេខ **D97/14/15,** សាធារណៈ, សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការ អនុវត្តសហកម្មឧក្រិដ្ឋកម្មរួម (JCE), ថ្ងៃទី២០ ឧសភា ២០១០, ERN00486521-00486589 ត្រង់កថាខណ្ឌទី ៣២ (*ដោយបានស្រង់សម្តី រដ្ឋអាជ្ញា ទល់នឹង Kupreškić, កំណត់សម្គាល់ខាងលើ* លេខ ៥, ត្រង់កថាខណ្ឌទី ៨៨) ។

[8] មាត្រា១៤.៣.ក, អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ។

[9] ឯកសារលេខ **D97/14/15,** សាធារណៈ, សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម (JCE), ថ្ងៃទី២០ ឧសភា ២០១០, ERN00486521-00486589 ត្រង់កថាខណ្ឌទី ៣២ (*ដោយបានស្រង់សម្តី រដ្ឋអាជ្ញា ទល់នឹង Hadžihasanović, Alagić and Kubura*, សំណុំរឿងលេខ IT-01-47-PT, សេចក្តីសម្រេចលើទម្រង់នៃដីកា បញ្ជូនរឿងទៅជំនុំជម្រះ, ថ្ងៃទី៧ ធ្នូ ២០០១, ត្រង់កថាខណ្ឌទី ៨) ។

ឡាយដែលត្រូវបានលើកឡើងចោទប្រកាន់ត្រូវបានគេប្រព្រឹត្ត, (v) អំឡុងពេលដែលនៅក្នុងអំឡុងពេលនោះអំពើឬព្រឹត្តិការណ៍ទាំងឡាយដែលបានលើកឡើង បង្កើតបានជាឧក្រិដ្ឋកម្មនានាដែលបានកើតឡើង, (vi) រយៈនៃពេលវេលាក្នុងចន្លោះការកើតឡើងនៃព្រឹត្តិការណ៍ទាំងនោះ និងការបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះ, និង (vii) ការបូកសរុបនៃកាលៈទេសៈនៅជុំវិញការប្រព្រឹត្តនូវឧក្រិដ្ឋកម្មនានាដែលបានលើកឡើងចោទប្រកាន់[10]។ វិសាលភាពនៃឧក្រិដ្ឋកម្មនានាដែលត្រូវបានលើកឡើងចោទប្រកាន់កាន់តែធំកាលណា តម្រូវការកំរិតខ្ពស់នៃភាពជាក់លាក់ពីអត្តសញ្ញាណរបស់ជនរងគ្រោះ និងពេលវេលា និងទីកន្លែងនៃព្រឹត្តិការណ៍នានាដែលត្រូវបានលើកឡើងចោទប្រកាន់ កាន់តែមិនអាចអនុវត្តបានកាលនោះដែរ[11]។ ចារីទាំងឡាយនៃឧក្រិដ្ឋកម្មនានាអាចនឹងត្រូវបានកំណត់អត្តសញ្ញាណ ដោយការយោងទៅដល់ប្រភេទ ឬក្រុមរបស់ពួកគេ ខណៈដែលជនជាប់ចោទត្រូវបានដកចេញយ៉ាងឆ្ងាយពីព្រឹត្តិការណ៍ទាំងនោះ[12] ។

### *អង្គហេតុសំខាន់ៗដែលមានមូលដ្ឋាននៅលើការទាញសេចក្តីសន្និដ្ឋាន*

៨. អង្គហេតុសំខាន់ៗអាចត្រូវបានបង្ហាញសក្ខីកម្ម ដោយការទាញសេចក្តីសន្និដ្ឋានចេញពីភស្តុតាងប្រយោល។ ចំពោះសក្ខីកម្មនៃអង្គហេតុនោះនៅពេលសវនាការការទាញសេចក្តីសន្និដ្ឋានត្រូវតែជាសេចក្តីសន្និដ្ឋានដ៏សមហេតុសមផល ដែលមានមូលដ្ឋាននៅលើភស្តុតាងនោះប៉ុណ្ណោះ។ វិធីទាញសេចក្តីសន្និដ្ឋាន ធ្លាប់ត្រូវបានគេប្រើប្រាស់ដើម្បីបង្ហាញសក្ខីកម្មពីស្ថានភាពផ្លូវចិត្ត នៃជនជាប់ចោទដែលគេបានតម្រូវឱ្យមាន[13]។ ដោយឡែក សក្ខីកម្មពីទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោមរបស់ជនជាប់ចោទណាម្នាក់[14] និងការដឹងឮពិតប្រាកដពីអំពើ ឧក្រិដ្ឋរបស់ថ្នាក់ក្រោមខ្លួន[15] អាចនឹងត្រូវបានបង្កើតឡើងតាមរយៈភស្តុតាងផ្ទាល់ ឬប្រយោល។

---

10 រដ្ឋអាជ្ញា ទល់នឹង Sesay, សំណុំរឿងលេខ SCSL-2003-05-PT, សេចក្តីសម្រេច និងដីកាបង្គាប់លើញត្តិបឋមរបស់មេធាវីការពារក្តីស្តីពីកំហុសនីតិវិធីនៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ, ថ្ងៃទី១៣ តុលា ២០០៣, កថាខណ្ឌទី ៨ ។

11 ដដែលដូចមុន, ត្រង់កថាខណ្ឌទី ៧(v) (ដោយបានស្រង់សម្តី Ntakirutimana, សាលក្រម និងការផ្តន្ទាទោស, សំណុំរឿងលេខ ICTR-96-10 និង 196-17-T, ថ្ងៃទី២ កុម្ភៈ ២០០៣ ) ។

12 ដូចមុនដដែល, ត្រង់កថាខណ្ឌទី ៧(v) (ដោយបានស្រង់សម្តី Nahimana, សំណុំរឿងលេខ ICTR-96-11-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីស្តីពីកំហុសនីតិវិធីនៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានផ្លាស់ប្តូរ, ថ្ងៃទី១៧ វិច្ឆិកា ១៩៩៨) ។

13 រដ្ឋអាជ្ញា ទល់នឹង Ntagerura,កំណត់សម្គាល់ខាងលើ លេខ៣, ត្រង់កថាខណ្ឌទី ៣០៤, ៣៩៩ (ដោយបានលើកឡើងពីសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ Vasiljevic, កថាខណ្ឌទី ១២០ ។ បណ្តឹងឧទ្ធរណ៍របស់ Krstic, កថាខណ្ឌទី ៤១ ។ បណ្តឹងឧទ្ធរណ៍របស់ Kvocka និងគូកន, កថាខណ្ឌទី ២៣៧ ។ បណ្តឹងឧទ្ធរណ៍របស់ Stakic, កថាខណ្ឌទី ២១៩ ។

14 រដ្ឋអាជ្ញា ទល់នឹង Kordic, សំណុំរឿងលេខ IT-95-14/2-T, សេចក្តីសម្រេច, ថ្ងៃទី២៦ កុម្ភៈ ២០០១, កថាខណ្ឌទី ១៣ ។

15 រដ្ឋអាជ្ញា ទល់នឹង Ntagerura, សំណុំរឿងលេខ IT-99-46-A, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍, ថ្ងៃទី៧ កក្កដា ២០០៦, ត្រង់កថាខណ្ឌទី ៤២៧ ។

៩. នៅក្នុងករណី *រដ្ឋអាជ្ញា ទល់នឹង Ntagerura* តុលាការ ICTR បានពន្យល់ថា "ករណីតាមកាលៈទេសៈ មានភស្តុតាងមួយចំនួនស្តីពីកាលៈទេសៈខុសៗគ្នាដែលថា បើដាក់ចូលគ្នាទៅ ចង្អុលពីពិរុទ្ធភាពរបស់ជនជាប់ចោទ ពីព្រោះជាទូទៅវាមានអត្ថិភាពតែនៅក្នុងការដាក់បញ្ចូលគ្នាប៉ុណ្ណោះ ពីព្រោះជនជាប់ចោទបានធ្វើនូវអ្វីដែលគេបានលើកឡើងចោទប្រកាន់ប្រឆាំងនឹងរូបគាត់"[16]។ យោងទៅតាមតុលាការនេះ "សេចក្តីសន្និដ្ឋានពីពិរុទ្ធភាពអាចត្រូវបាន(យល់ឃើញ)ទាញជាសេចក្តីសន្និដ្ឋានចេញពីភស្តុតាងប្រយោល"[17] ឲ្យតែសេចក្តីសន្និដ្ឋាននេះ "ជាសេចក្តីសន្និដ្ឋានដ៏សមហេតុសមផល ដែលអាចមានពីអង្គហេតុនោះ*តែប៉ុណ្ណោះ*" និង "ត្រូវបានបង្កើតឡើងឲ្យបានហួសពីវិមតិសង្ស័យ"[18] ។

១០. ដូចនៅក្នុងករណីរឿងក្តីរបស់ Al Bashir ដែលខាងអយ្យការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការខកខានរបស់អង្គបុរេជំនុំជម្រះ ក្នុងការចេញដីកាបង្គាប់ឲ្យនាំខ្លួនមួយបើសិនជាបទដ្ឋានស្តីពីភស្តុតាងដែលលក្ខខណ្ឌបានតម្រូវនៅក្នុងដំណាក់កាលបឋមនៃដំណើរការនីតិវិធីនេះ គឺជា "មូលហេតុដ៏សមហេតុផលដើម្បីធ្វើឲ្យជឿជាក់ថា "ជនជាប់ចោទបានប្រព្រឹត្តបទល្មើសដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការនេះ[19]។ អង្គបុរេជំនុំជម្រះបានបកស្រាយខុសអំពីបទដ្ឋាននេះទាក់ទងអំពីចេតនាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍របស់ជនជាប់ចោទ ដោយផ្អែកលើភស្តុតាងនៃ "សក្ខីកម្មដែលបានមកដោយសារការទាញសេចក្តីសន្និដ្ឋាន"[20]។ អង្គបុរេជំនុំជម្រះ បានរកឃើញដោយមិនត្រឹមត្រូវថា ដីកាបង្គាប់ឲ្យនាំខ្លួនអាចនឹងចេញបានតែនៅក្នុងករណី បើសិនជាភស្តុតាងដែលផ្តល់ដោយរដ្ឋអាជ្ញា "បង្ហាញថា សេចក្តីសន្និដ្ឋានដ៏សមហេតុសមផលតែមួយគត់ដែលត្រូវទាញ ចេញពីនេះ គឺជាអត្ថិភាពនៃមូលហេតុដ៏សមហេតុសមផលដើម្បីធ្វើឲ្យជឿជាក់"ទៅលើអត្ថិភាព នៃចេតនា ជាក់លាក់ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍តែប៉ុណ្ណោះ"[21]។

១១. អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា៖

> "ការតម្រូវឲ្យមានអត្ថិភាពនៃចេតនាប្រល័យពូជសាសន៍ ត្រូវតែជាការសន្និដ្ឋានដ៏សមហេតុសមផលតែមួយគត់ ឈានឡើងដល់ការតម្រូវឲ្យរដ្ឋអាជ្ញាធ្វើការបង្ហាញថាមិនយល់ព្រមសេចក្តីសន្និដ្ឋានដ៏សមហេតុសមផលដទៃទៀតណាមួយក៏ដោយ និងធ្វើការ

---

16 រដ្ឋអាជ្ញា ទល់នឹង Ntagerura, កំណត់សម្គាល់ខាងលើ លេខ៣, ត្រង់កថាខណ្ឌទី ៣០៤ ។

17 អាជ្ញា ទល់នឹង Ntagerura, កំណត់សម្គាល់ខាងលើ លេខ៣, ត្រង់កថាខណ្ឌទី ៣០៦ ។

18 អាជ្ញា ទល់នឹង Ntagerura, កំណត់សម្គាល់ខាងលើ លេខ៣, ត្រង់កថាខណ្ឌទី ៣០៤-៦ ។

19 វិធាន៥១ នៃវិធានផ្ទៃក្នុង ។

20 រដ្ឋអាជ្ញា ទល់នឹង Omar Hassan Ahmad Al Bashir, ICC-02/05-01/09-OA, ស្ថានភាពនៅដាហ្វួ, ប្រទេសស៊ូដង់, សាលក្រមលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាប្រឆាំងនឹង "សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញា ឲ្យចេញដីកាចាប់ខ្លួន Omar Hassan Ahmad al Bashir", ៣ កុម្ភៈ ២០១០, ត្រង់កថាខ័ណ្ឌទី៣៩ ។

21 ក្នុងឯកសារដដែលដូចខាងលើ, ត្រង់កថាខ័ណ្ឌទី៣២ ។

បំបាត់ចោលនូវ វិមតិសង្ស័យណាមួយក៏ដោយ។ ប្រសិនបើសេចក្ដីសន្និដ្ឋានដ៏សមហេតុសមផលតែមួយ គត់ដែលមានមូលដ្ឋាននៅលើភស្តុតាង នោះគឺអត្ថិភាពនៃចេតនាប្រល័យពូជសាសន៍នោះ ដូច្នោះវាមិនអាចត្រូវបានគេនិយាយបានទេថា ការរកឃើញបែបនោះបង្កើតបានត្រឹមតែ "ទទ្បីករណ៍ដ៏សមហេតុសមផលដែលជឿជាក់បាន"។ *ផ្ទុយទៅវិញ វាបង្កើតបានជាចេតនាប្រល័យពូជសាសន៍ដែល "ហួសពីវិមតិសង្ស័យ* (សង្កត់ន័យបន្ថែមដោយអក្សរ ទ្រេត)"[22] ។

១២. តម្រូវការឱ្យមានសក្ខីកម្ម "ហួសពីវិមតិសង្ស័យ" នៅអវតក គឺជាបមាណីយភស្តុតាងដែលបានតម្រូវឱ្យមានដើម្បីរកពិរុទ្ធភាពនៅពេលធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់នៃដំណើរការនីតិវិធី ខណៈដែលគ្រប់ភស្តុតាងទាំងអស់ត្រូវបានស្ដាប់រួចហើយ មិនមែននៅពេលចាប់ផ្ដើមធ្វើដំណើរការនីតិវិធីសវនាការលើអង្គសេចក្ដីនោះទេ[23] ។ អាស្រ័យហេតុដូច្នេះ អំណះអំណាងរបស់មេធាវីការពារក្ដីគឺខុសដែលថា ខណៈដែលចេតនាប្រល័យពូជសាសន៍ដែលមានមូលដ្ឋាននៅលើភស្តុតាងប្រយោលត្រូវបានលើកថ្លែងសំអាងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមួយ វាត្រូវតែជា *"ការទាញសេចក្ដីសន្និដ្ឋានដ៏សមហេតុសមផលតែប៉ុណ្ណោះ"* ។ បមាណីយនេះអនុវត្តនៅចុងបញ្ចប់នៃសវនាការនៅពេលដែលគ្រប់ភស្តុតាងទាំងអស់ត្រូវបានស្ដាប់រួចហើយ និងពិរុទ្ធភាពរបស់ជនជាប់ចោទ កំពុងត្រូវបានកំណត់ មិនមែននៅពេលធ្វើការកំណត់ពីសុពលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ។ គ្រប់អ្វីៗទាំងអស់ដែលគេបានតម្រូវឱ្យមានពាក់ព័ន្ធទៅនឹងដីកាដំណោះស្រាយ នោះគឺថាចេតនាប្រល័យពូជសាសន៍គឺជាការទាញសេចក្ដីសន្និដ្ឋានដ៏សមហេតុសមផលមួយចេញពីភស្តុតាងនៅក្នុងករណីរឿងនោះ។

## *បទចោលដែលឆ្លាស់គ្នា*

១៣. បទចោទដែលឆ្លាស់គ្នានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម និងជាពិសេសពាក់ព័ន្ធនឹងទម្រង់នៃការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌធ្លាប់អនុវត្តនៅ អវតក នៅក្នុងដីកាដំណោះស្រាយរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ។ ការអនុវត្តនេះដែលបានទទួលយល់ព្រមដោយអង្គបុរេជំនុំជម្រះនៅលើបណ្ដឹងឧទ្ធរណ៍[24] ក៏ជាការអនុវត្តនៅក្នុងតុលាការអន្តរជាតិស្រដៀងគ្នានឹង

22 ដូចមុនដដែល, កថាខ័ណ្ឌទី៣៣ ។

23 វិធាន៨៧.១ នៃវិធានផ្ទៃក្នុង ។

24 ឯកសារលេខ D99, "ដីកាដំណោះស្រាយបញ្ជូនរឿង កាំង ហ្កេកអ៊ាវ ហៅ ឌុច ទៅជំនុំជម្រះ", ចុះថ្ងៃទី៨ សីហា ២០០៨, ERN 00210783-0860 ត្រង់ទំព័រ៤៤ , ក្នុងករណីអង្គជំនុំជំរះសាលាដំបូងបានធ្វើការចោទប្រកាន់ ឌុច ពីបទបាន "រៀបចំផែនការ, ញុះញង់, បញ្ជា, ប្រព្រឹត្ត ឬជួយនិងជំរុញ, ឬការទទួលខុសត្រូវតាមឋានានុក្រមការទទួលខុសត្រូវរបស់ថ្នាក់លើពីបទ...ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ...[និង] បទបំពានបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទាននាន់នៃទីក្រុងហ្សឺណែវឆ្នាំ១៩៤៩"។ ដោយមានការយល់ព្រមពី អង្គបុរេជំនុំជម្រះ ក្នុងករណីរឿងរបស់ កាំង ហ្កេកអ៊ាវ, ដែលថ្លែងថា "៨៦...ថាទាំងនៅក្នុងវិធានផ្ទៃក្នុងក្ដី ឬនៅក្នុងច្បាប់កម្ពុជាក្ដីគឺមិនមានបញ្ញត្តិណាដែលចែងទាក់ទងនឹងលទ្ធភាពក្នុងការកំណត់បទល្មើសផ្សេងពីគ្នាលើចំពោះតែមួយដដែលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ។ ហេតុដូចនេះ ដូចបានចែងកំណត់នៅ

អវតកដែរ ហើយក៏បានដោះស្រាយពីការរំលោភសិទ្ធិមនុស្សក្នុងទ្រង់ទ្រាយធំផងដែរ[25]។ បទចោទត្រួតត្រូវបានអនុញ្ញាត ដោយទាក់ទងនឹងអង្គហេតុពិតដែលថានៅមុនពេលការបង្ហាញគ្រប់ភស្តុតាងទាំងអស់ វាមិនអាចធ្វើការកំណត់បានពីភាពជាក់លាក់មួយ ដែលថាតើបទចោទណាមួយដែលបានធ្វើឡើងប្រឆាំងនឹងជនជាប់ចោទត្រូវបានធ្វើសក្ខីកម្ម[26]។ ការធ្វើសេចក្តីថ្លែងសំអាងពីទម្រង់ផ្សេងៗគ្នានៃការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌ ដែលជាការផ្លាស់គ្នាធ្លាប់ត្រូវបានទទួលស្គាល់ជាទូទៅនៅក្នុងកំរិតអន្តរជាតិ[27] ។

*ការបកស្រាយពីបរិបទដែលបានតម្រូវ*

១៤. នៅពេលធ្វើការវាយតម្លៃពីសុពលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ វាជាមូលដ្ឋានគ្រឹះដែលថាកថាខណ្ឌនានានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ *"...មិនគួរត្រូវបានពិចារណាដាច់ដោយឡែកពីគេនោះទេ ប៉ុន្តែគួរត្រូវបានពិចារណានៅក្នុងបរិបទនៃកថាខណ្ឌផ្សេងៗទៀត នៅក្នុងដីកាបញ្ជូនរឿង*

---

ក្នុងមាត្រា១២ នៃកិច្ចព្រមព្រៀង គឺអង្គបុរេជំនុំជម្រះអាចស្វែងរកការណែនាំនៅក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងនៅក្នុងកំរិតអន្តរជាតិ។ ៨៧. យុត្តិសាស្ត្ររបស់តុលាការពិសេស អន្តរជាតិនានា បានសម្រេចថា នៅក្នុងដំណើរការនីតិវិធីលើរឿងក្តីព្រហ្មទណ្ឌអន្តរជាតិ គេអាចអនុញ្ញាតឲ្យដាក់បញ្ចូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនូវបទល្មើសដែលផ្សេងពីគ្នាបានទាក់ទងនឹងអំពើតែមួយដដែល [លេខយោងជើងទំព័រត្រូវបានដកចេញ]។ ទាំងតុលាការ ICTY និងទាំងតុលាការ ICTR ក្តី សុទ្ធតែមានយុត្តិសាស្ត្រដ៏ច្រើនសន្ធឹកសន្ធាប់ ដែលគាំទ្រចំពោះការប្រើប្រាស់បទចោទដែលត្រួតគ្នា។ តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន (SCSL) ក៏បានយកតាមការអនុវត្តបែបនេះដែរ [លេខយោងជើងទំព័រត្រូវបានដកចេញ] ។ ត្រូវបានសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេត បានដាក់បញ្ចូលនៅក្នុងដីកាដំណោះស្រាយ ទាំងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផង និងទាំងអំពើបំពារបំពានលើអនុសញ្ញានានានៃទីក្រុងហ្សឺណែវផង ទាក់ទងនឹងអំពើតែមួយដដែល។ ៨៨. អង្គបុរេជំនុំជម្រះ បានធ្វើការកត់សំគាល់បន្ថែមទៀតថា ការដាក់បញ្ចូលនូវការកំណត់បទល្មើសដែលលើសពីមួយទាក់ទងនឹងអំពើតែមួយដដែល នៅក្នុដីកាបញ្ជូនរឿងទៅជំនុំជម្រះគឺមិនមែនជាការគំរាមកំហែងដែលមានជាប់មកជាមួយស្រាប់ ចំពោះគោលការណ៍ស្តីពីការកាត់ក្តីពីរដងលើបទល្មើសតែមួយ(ne bis in idem principle)នោះទេ ពីព្រោះមិនមានការចាត់តាំងជាក់ស្តែងអំពីការទទួលខុសត្រូវ ឬការដាក់ទណ្ឌកម្មនៅក្នុងនោះឡើយ [លេខយោងជើងទំព័រត្រូវបានដកចេញ]"។ (សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/កសចស(អបជ ០២), សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដំកាដំណោះស្រាយបញ្ជូនរឿង កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ទៅជំនុំជម្រះ, ចុះថ្ងៃទី៥ ធ្នូ ២០០៨, ឯកសារលេខ D99/3/42 , លេខ ERN 00249846-00249887, កថាខណ្ឌទី៨៦-៨៨ ។

25 ICTY: រដ្ឋអាជ្ញា ទល់នឹង Stanisic and Zupljanin, សំណុំរឿងលេខ IT-08-91-PT, ដីកាបញ្ជូនរឿងទៅជំនុំជម្រះរួមដែលបានផ្លាស់ប្តូរលើកទីពីរ, ត្រង់ទំព័រទី ១-៣ (ថ្ងៃទី១០ កញ្ញា ២០០៩) ។ SCSL: រដ្ឋអាជ្ញា ទល់នឹង Taylor, សំណុំរឿងលេខ SCSL-03-01-PT, ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានផ្លាស់ប្តូរលើកទីពីរ, ត្រង់ទំព័រទី ២-៧, ៩ (ថ្ងៃទី២៩ ឧសភា ២០០៧) ។ នៅក្នុងករណីទាំងពីរនេះ ការចូលរួមនៅក្នុង JCE ត្រូវបានលើកថ្លែងសំអាងនៅក្នុងការផ្លាស់គ្នាចំពោះទម្រង់ផ្សេងៗនៃការទទួលខុសត្រូវ ដូចជា ការធ្វើផែនការ ការញុះញង់ ការបញ្ជា ការជួយ និង ការជំរុញ ។

26 Delalic និងគូកន, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សេចក្តីសម្រេច, ថ្ងៃទី២០ កុម្ភៈ ២០០១ (ICTY) ។

27 Rasevic, សេចក្តីសម្រេចពាក់ព័ន្ធនឹងញត្តិបឋមរបស់មេធាវីការពារក្តីស្តីពីទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ICTY), ថ្ងៃទី២៨ មេសា ២០០៤, កថាខណ្ឌទី ២៩ ។ Mrksic, សេចក្តីសម្រេចលើទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ICTY), ថ្ងៃទី១៩ មិថុនា ២០០៣, កថាខណ្ឌទី ៦២ ។

*ទៅជំនុំជម្រះ* "[28] ។ ការណ៍នេះ មានមែកធាងចេញមកពីគោលការណ៍ទូទៅក្នុងការបកស្រាយច្បាប់ដែលចែងនៅក្នុងឯកសារនានា គឺត្រូវតែបានបកស្រាយដោយសុចចិត្ត ឱ្យត្រូវទៅតាមនិយមន័យធម្មតានៅក្នុងបរិបទរបស់វា និងដោយពាក់ព័ន្ធទៅនឹងកម្មវត្ថុ និងគោលបំណងរបស់វា[29] ។

## ខ. ការផ្លាស់ប្តូរបទចោទ

១៥. វិធាន៩៨.២ អនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការផ្លាស់ប្តូរការកំណត់បទចោទដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឱ្យតែការផ្លាស់ប្តូរការកំណត់បទចោទនោះ កម្រិតនៅត្រឹមតែអង្គហេតុនានា ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ៖

> "សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ ។ អង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទចោទ ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ ។ អង្គជំនុំជម្រះត្រូវធ្វើការវិនិច្ឆ័យតែចំពោះជនជាប់ចោទប៉ុណ្ណោះ"[30] ។

១៦. នៅក្នុងករណីរបស់ ឌុច អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា លទ្ធភាពនៃការកំណត់បទចោទដោយអនុលោមតាមវិធាន៩៨(២) មានរួមទាំងលទ្ធភាពក្នុងការផ្លាស់ប្តូរពីទម្រង់នៃការទទួលខុសត្រូវ ដែលបានចោទប្រកាន់ផងដែរ។

> "៤៩២. បញ្ហាជាបឋម អង្គជំនុំជម្រះកត់សម្គាល់ថា អង្គជំនុំជម្រះមិនជាប់កាតព្វកិច្ចត្រូវអនុវត្តតាមការកំណត់បទចោទប្រកាន់ ដែលបានសម្រេចដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលត្រូវបានធ្វើការកែប្រែនោះទេ [.......] ។ ៤៩៦. ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា វិធាន៩៨(២)នៃវិធានផ្ទៃក្នុងអាចអនុញ្ញាតឱ្យអង្គជំនុំជម្រះផ្លាស់ប្តូរការកំណត់បទចោទ ដែលមានបញ្ហានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ដើម្បីឱ្យស្របជាមួយនឹងទម្រង់នៃការទទួលខុសត្រូវថ្មីមួយ ប្រសិនបើមានការផ្លាស់ប្តូរការកំណត់បទចោទ ។ នៅពេលមានការផ្លាស់ប្តូរការកំណត់បទចោទ អង្គជំនុំជម្រះត្រូវតែធានាផងដែរថា (i) មិនមានការរំលោភសិទ្ធិ

28 រដ្ឋអាជ្ញា ទល់នឹង Ntagerura, សំណុំរឿងលេខ ICTR-99-46-T, សាលក្រម និងការផ្តន្ទាទោស, ថ្ងៃទី២៥ កុម្ភៈ ២០០៤, កថាខណ្ឌទី ៣០ ។ សូមមើលផងដែរ រដ្ឋអាជ្ញា ទល់នឹង Rutaganda, សំណុំរឿងលេខ ICTR-96-3-A, សេចក្តីសម្រេច, ថ្ងៃទី២៦ ឧសភា ២០០៣, កថាខណ្ឌទី ៣០៤ ។

29 មាត្រា៣១.១, អនុសញ្ញាទីក្រុងវីយ៉ែនស្តីពីច្បាប់សន្ធិសញ្ញា, ឆ្នាំ១៩៦៩ ។

30 សូមមើល វិធាន៩៨.២ នៃវិធានផ្ទៃក្នុង ។

របស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និង (ii) ទម្រង់នៃការទទួលខុសត្រូវថ្មីនោះ អាចយកមកអនុវត្តបាននៅ អវតក"[31] ។

១៧. លទ្ធភាពរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់បទចោទ រួមទាំងទម្រង់នៃការទទួលខុសត្រូវដែលបានចោទប្រកាន់ផង គឺមានភាពរលូនទៅនឹងការអនុវត្តនូវប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៃប្រទេសបារាំង[32] និងនីតិវិធីនៃតុលាការ ICC ផងដែរ[33] ។

## IV. ឧក្រិដ្ឋកម្មជាតិ

១៨. មេធាវីការពារក្តីតវ៉ាថា គ្រប់សេចក្តីយោងទាំងអស់ចំពោះឧក្រិដ្ឋកម្មជាតិកម្ពុជា គួរត្រូវបានដកចេញពីដីកាដំណោះស្រាយពីព្រោះ "ពុំមានអង្គហេតុណាត្រូវបានចែងដើម្បីគាំទ្រដល់ការបញ្ចូលឧក្រិដ្ឋកម្ម"[34] ។ នេះជាការមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែត ។ គ្រប់ឧក្រិដ្ឋកម្មជាតិនិមួយៗគឺជាធាតុផ្សំដ៏ចាំបាច់មួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលជនជាប់ចោទត្រូវបានចោទប្រកាន់: វាគឺជា "ធាតុផ្សំមជ្ឈត្តិក"[35] ចំពោះឧក្រិដ្ឋកម្មទាំងនេះ ។ ហេតុដូច្នេះឧក្រិដ្ឋកម្មនៃ "ការធ្វើមនុស្សឃាត" ត្រូវបានចែងថាជា "បទល្មើសជាដើមចម" ដែលបង្កើតឱ្យមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[36] ឬ "ការបំពារបំពានយ៉ាងធ្ងន់ធ្ងរ"[37] ដូចគ្នានឹង "ការធ្វើទារុណកម្ម"[38] ខណៈ"ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា" ត្រូវបានកំហិតចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[39]។

31 ឯកសារលេខ E188, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសដ, កាំង ហ្គេកអ៊ាវ ហៅ ឌុច, អង្គជំនុំជម្រះសាលាដំបូង ។

32 សូមមើលមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ "បើការពិភាក្សាបង្ហាញថាអង្គហេតុមានការកំណត់បទចោទមួយផ្សេងទៀតក្រៅពី បទចោទដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លោកប្រធានត្រូវសួរសំណួរជំនួយមួយ ឬច្រើនបន្ថែមទៀត" ។

33 សូមមើលបទបញ្ជាផ្ទៃក្នុងលេខ ៥៥ នៃតុលាការ ICC (អំណាចនៃអង្គជំនុំជម្រះក្នុងការផ្លាស់ប្តូរការកំណត់បទចោទនៃអង្គហេតុនានា) "២. នៅពេលណាមួយក៏ដោយក្នុងអំឡុងពេលសវនាការ វាទំនងជាថា ការកំណត់បទចោទនៃអង្គហេតុអាចនឹងត្រូវបានផ្លាស់ប្តូរនោះ អង្គជំនុំជម្រះត្រូវជូនដំណឹងដល់អ្នកចូលរួមនានាអំពីលទ្ធភាពបែបនោះ ហើយនិងធ្វើការស្តាប់ភស្តុតាង នៅពេលសមស្របណាមួយនៃដំណើរការនីតិវិធីត្រូវផ្តល់ដល់អ្នកចូលរួមនូវឱកាសដើម្បីធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ ឬជាលាយលក្សអក្សរ" ។

34 ញត្តិស្នើសុំលុបចោល, កថាខ័ណ្ឌទី៣ ។

35 De Salvador Torres ទល់នឹង ប្រទេសអេស្បាញ, (1997) 23 E.H.R.R. 601, កថាខ័ណ្ឌទី 33; Block ទល់នឹង Hungary, ECHR លេខ 56282/09, ២៥ មករា ២០១១, កថាខ័ណ្ឌទី២៤ ។

36 ដីកាដំណោះស្រាយ, កថាខ័ណ្ឌទី១៣៧៣-១៣៨០ ។

37 ដីកាដំណោះស្រាយ, កថាខ័ណ្ឌទី១៤៩១-១៤៩៧ និង១៤៩៨-១៥០០ ។

38 ដីកាដំណោះស្រាយ, កថាខ័ណ្ឌទី១៤០៨-១៤១៤ ។

39 ដីកាដំណោះស្រាយ, កថាខ័ណ្ឌទី១៤១៩-១៤២១ ។

១៩. មេធាវីការពារក្តីក៏តវ៉ាផងដែរថា "គ្មានទម្រង់នៃការទទួលខុសត្រូវដែលមាននៅក្នុងបញ្ជី អនុវត្តបានចំពោះឧក្រិដ្ឋកម្ម [ជាតិ] ទាំងនេះទេ"[40] ។ ទាក់ទិននឹងការតវ៉ានេះ វាជាការសន្និដ្ឋានដែលគ្មានតក្កៈភាព" ដើម្បីតវ៉ាថា ការមិនអនុវត្តនៃទម្រង់នៃការទទួលខុសត្រូវជាអន្តរជាតិ ចំពោះឧក្រិដ្ឋកម្មជាតិ[41] ធ្វើឱ្យប៉ះពាល់ដល់សុពលភាពនៃបទចោទទាំងនេះ ។ ជាការច្បាស់ណាស់ថា ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌខ្លះ ដែលអាចអនុវត្តបាននៅកម្ពុជាក្នុងពេលដែលពាក់ព័ន្ធ មានលក្ខណៈសទិសភាពទៅនឹងទម្រង់នៃការទទួលខុសត្រូវជាក់លាក់នៅថ្នាក់អន្តរជាតិ ។ ដូច្នេះ ជាឧទាហរណ៍ដូចជាថា ការចាក់រុក ឬការនាំអាទិ៍[42] ជាពាក្យសទិសភាពទៅនឹង "ការញុះញង់"[43] ចំណែកពាក្យថា "ការជួយជ្រុំជ្រែង និងការទំនុកបម្រុង" ឬ "ការជួយ និងការទំនុកបម្រុង"[44] គឺដូចគ្នាដោយផ្ទាល់ទៅនឹងពាក្យ "ការជួយ និងការទំនុកបម្រុង"[45] ដែរ ។ នេះគឺជាករណីចំពោះការអះអាងដែលថាមាន "កង្វះ" នូវភាពជាក់លាក់អំពីទម្រង់នៃការទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មជាតិ គឺដូចគ្នាទៅនឹងបទឧក្រិដ្ឋទាំងនេះដែរ ។ គេគ្មានការកំហិតចំពោះការប្រើធាតុផ្សំនៃអង្គហេតុដូចគ្នា ដើម្បីបង្ហាញឱ្យឃើញនូវបទចោទផ្សេងទេ ហើយអង្គជំនុំជម្រះសាលាដំបូងទទួលបានអំណាចដើម្បីធ្វើការកំណត់បទចោទឡើងវិញស្របទៅតាមនោះ ។ ដោយសារឧក្រិដ្ឋកម្មជាតិជា "ធាតុផ្សំមជ្ឈន្តិក" ចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ហើយទម្រង់នៃការទទួលខុសត្រូវជាតិ គឺជាសទិសភាពទៅនឹងទម្រង់នៃការទទួលខុសត្រូវអន្តរជាតិដូចបានគូសបញ្ជាក់រួចហើយ គឺគ្មានបុរេវិនិច្ឆ័យចំពោះជនជាប់ចោទតាមរយៈការមិនបានកំណត់ឱ្យបានលម្អិតអំពីការអនុវត្តចំពោះអង្គហេតុពិតនានានោះឡើយ[46] ។

## V. អំពើប្រល័យពូជសាសន៍

២០. មេធាវីការពារក្តីតវ៉ាថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កង្វះនូវភាពជាក់លាក់ចំពោះចេតនាជាក់លាក់របស់ជនជាប់ចោទក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍។ ពួកគេតវ៉ាថា សហចៅក្រមស៊ើបអង្កេតមានការភាន់ច្រឡំចំពោះ "ការរកឃើញថា" ចេតនាប្រល័យពូជសាសន៍ជា"ការយល់ឃើញ" ដោយពុំមានការរកឃើញថា"ការយល់ឃើញដែលមានហេតុផលតែមួយគត់នៅលើភស្តុតាងដែលមាន"[47]។ ដូចបានពិភាក្សាខាងលើអំណះអំណាងនេះគឺជាការភាន់ច្រឡំ។ គេអនុញ្ញាតឱ្យទាញយកការយល់ឃើញពីភស្តុតាងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប្រសិនបើការយល់ឃើញនោះ

40 ញត្តិស្នើសុំលុបចោល, កថាខណ្ឌទី៣ ។

41 ញត្តិស្នើសុំលុបចោល, កថាខណ្ឌទី៤ ។

42 មាត្រា៨៣, ៨៤ និង២៩៩ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ ។

43 ដីកាដំណោះស្រាយ, កថាខណ្ឌទី១៥៤៧-១៥៤៩ ។

44 មាត្រា៨៣ និង៨៧ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ ។

45 ដីកាដំណោះស្រាយ, កថាខណ្ឌទី១៥៥០-១៥៥២ ។

46 De Salvador Torres ទល់នឹង ប្រទេសអេស្ប៉ាញ, ដូចខាងលើ កំណត់សំគាល់២៩, កថាខណ្ឌទី 33; Block ទល់នឹង Hungary, ដូចខាងលើ កំណត់សំគាល់២៩, កថាខណ្ឌទី២៤ ។

47 ញត្តិស្នើសុំលុបចោល, កថាខណ្ឌទី៧ ។

សមហេតុផល។ មេធាវីការពារក្តីមិនបានតវ៉ាថា ការយល់ឃើញទាំងនេះ គ្មានហេតុផលទេ; គ្មានតម្រូវការអំពីភាពជាក់លាក់បន្ថែមទេ ។

២១. មេធាវីការពារក្តីតវ៉ាទៀតថា សហចៅក្រមស៊ើបអង្កេត បានខកខានមិនបានផ្តល់ចំណុចជាក់លាក់គ្រប់គ្រាន់ដើម្បីបង្ហាញឲ្យឃើញថា មាន "ការព្រមព្រៀងពិតប្រាកដដើម្បីប្រព្រឹត្តអំពើប្រល័យពូជសាសន៍"[48] បើសិនជនជាប់ចោទត្រូវបានចោទប្រកាន់តាមរបៀបមួយផ្សេង។ វាជាការមិនត្រឹមត្រូវដោយហេតុថា អង្គហេតុចាំបាច់នានាដើម្បីកំណត់អំពីផែនការរួមមួយ ដែលជាលក្ខខណ្ឌតម្រូវសម្រាប់សហកម្មឧក្រិដ្ឋកម្មរួម ចាំបាច់បង្កប់នូវ "ការព្រមព្រៀង ដើម្បីប្រព្រឹត្តអំពើប្រល័យពូជសាសន៍"[49] ។ ដូច្នេះ ដូចដីកាដំណោះស្រាយយោងទៅលើ "ផែនការកម្ទេចចាម"[50] និង "គោលនយោបាយកម្ទេចវៀតណាម"[51] និងការចូលរួមពាក់ព័ន្ធរបស់ជនជាប់ចោទនៅក្នុងផែនការទាំងនេះ គឺជាអត្ថិភាពនៃការព្រមព្រៀងគ្នាមួយដែលត្រូវបានគេសន្មតថា មានពិតមែន[52]។

២២. មេធាវីការពារក្តីលើកយោងបណ្តឹងសាទុក្ខរបស់ **Krstić**[53] ជាការបង្ហាញឲ្យឃើញថា "ការដឹងឮ និងការ ទទួលយកអំពើប្រល័យពូជសាសន៍ មិនមានតម្លៃស្មើនឹងចេតនាជាក់លាក់ដើម្បីកម្ទេចទាំងស្រុង ឬមួយផ្នែកនៃក្រុម"ណាមួយនោះទេ[54] ។ ប៉ុន្តែ បណ្តឹងសាទុក្ខរបស់ **Krstić** មិនមាននិយាយអំពី "ការទទួលយក"ទេ គឺមានពាក់ព័ន្ធតែនឹង "ការដឹងឮ" ប៉ុណ្ណោះ។ ការណ៍នេះបានធ្វើឲ្យរឹតតែច្បាស់ សូម្បីក្នុងប្រយោគដែលមេធាវីការពារក្តីជ្រើសរើសធ្វើជាសេចក្តីយោងដើម្បីគាំទ្រចំពោះអំណះអំណាងរបស់ខ្លួនក៏ដោយ, ដែលថ្លែងថា "... ការដឹងឮ... តែមួយគត់មិនអាចគាំទ្រចំពោះការយល់ឃើញអំពីចេតនាប្រល័យពូជសាសន៍"[55] ។

២៣. ការពិត នៅក្នុងកថាខណ្ឌដំបូងៗនៃសាលក្រមបណ្តឹងសាទុក្ខរបស់ Krstic បង្ហាញឲ្យឃើញថាស្ថានភាពផ្លូវចិត្តរបស់គាត់ គឺផ្ទុយគ្នាស្រឡះពីការព្រមព្រៀង: គាត់បានព្យាយាមធានាសុវត្ថិភាពជូនជនមូស្លីមបូស្នី[56] ដោយគាត់បានបញ្ជាថា "ក្បួនជនស៊ីវិលត្រូវប្រព្រឹត្តទៅក្នុងរបៀបអរិយធម៌ ដើម្បី

---

48 ញត្តិស្នើសុំលុបចោល, កថាខ័ណ្ឌទី១០ ។

49 Prosecutor ទល់នឹង Milutinović, Šainović, និង Ojdanić, សំណុំរឿងលេខ. IT-99-37-AR72, សេចក្តីសម្រេចលើញត្តិស្នើសុំរបស់ Dragoljub Ojdanić's តវ៉ាអំពីយុត្តាធិការ - សហកម្មឧក្រិដ្ឋកម្មរួម, ២១ ឧសភា ២០០៣, កថាខ័ណ្ឌទី២៣ ។

50 ដីកាដំណោះស្រាយ, កថាខ័ណ្ឌទី១៣៣៩ ។

51 ដីកាដំណោះស្រាយ, កថាខ័ណ្ឌទី១៣៤៦ ។

52 Brdjanin & Talić, សំណុំរឿងលេខ. IT-99-36-PT, សេចក្តីសម្រេចលើទម្រង់នៃដីកាជញ្ជូនរឿងទៅជំនុំជម្រះដែលបានកែប្រែលើកទីបួន, ២៣ វិច្ឆិកា ២០០១, កថាខ័ណ្ឌទី១២ ។

53 រដ្ឋអាជ្ញា ទល់នឹង Krstić, សំណុំរឿងលេខ. IT-98-33-A, សាលក្រម, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ១៩ មេសា ២០០៤ ។

54 ញត្តិស្នើសុំលុបចោល, កថាខ័ណ្ឌទី២៧ ។

55 រដ្ឋអាជ្ញា ទល់នឹង Krstić, ដូចខាងលើ កំណត់សំគាល់៤៩, ត្រង់កថាខ័ណ្ឌទី១៣៤ ។

56 រដ្ឋអាជ្ញា ទល់នឹង Krstić, ដូចខាងលើ កំណត់សំគាល់៤៩, ត្រង់កថាខ័ណ្ឌទី១៣២ ។

00652159



ទប់ស្កាត់ "ប្រភេទនៃបញ្ហាដែលធ្លាប់កើតមានពីមុន"[57] ហើយគាត់ចាប់ផ្តើមខឹងនៅពេលមានគេប្រាប់គាត់អំពីការសម្លាប់ជនមូស្លីម[58]។ ស្ថានភាពនោះខុសគ្នាយ៉ាងខ្លាំងពីករណីនៅទីនេះ គឺថាគ្មានការលើកឡើងនៅក្នុងដីកាដំណោះស្រាយដែលថា ជនជាប់ចោទមិនបានឯកភាពទៅនឹងគោលនយោបាយប្រល័យពូជសាសន៍ទេ។ ដីកាដំណោះស្រាយលើកយោងពី "ការទទួលយកការបង្កើនមធ្យោបាយប្រព្រឹត្តឧក្រិដ្ឋកម្ម រួមជាមួយនឹងការមានះក្នុងការអនុវត្ត..."[59]។ វាជាការសមហេតុសមផល ដើម្បីយល់ឃើញពីចេតនាប្រល័យពូជសាសន៍ជាក់លាក់ដែលកើតចេញពីកាលៈទេសៈទាំងនេះ ។ ដូចលើកយកមកពិភាក្សាពីខាងលើ បើសិនការយល់ឃើញមានហេតុផលនោះ គឺជាការគ្រប់គ្រាន់ដើម្បីកំណត់អំពីចេតនាទៅនឹងបទដ្ឋានឃើញមួយក្រឡេកភ្នែក។

២៤. មេធាវីការពារក្តីតវ៉ាថា ដីកាដំណោះស្រាយមិនបានកំណត់បទចោទគ្រប់គ្រាន់ថាតើ "អំពើប្រល័យពូជសាសន៍ណាមួយដែល អៀង សារី ត្រូវបានចោទប្រកាន់"[60] និងមិនបានកំណត់ធាតុផ្សំរបស់វានិមួយៗទេ។ ត្រង់ចំណុចនេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ជាដំបូង គឺវាច្បាស់លាស់ហើយតាមពាក្យពេចន៍ក្នុងកថាខ័ណ្ឌទី១៥២៥(iv) នៃដីកាដំណោះស្រាយដែលថា ជនជាប់ចោទត្រូវបានចោទប្រកាន់ជាចំបងក្នុងការចូលរួមប្រព្រឹត្តក្នុងអំពើប្រល័យពូជសាសន៍ តាមរយៈការចូលរួមពាក់ព័ន្ធនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមរបស់ខ្លួន ។ បន្ទាប់មក សហព្រះរាជអាជ្ញាសន្និដ្ឋានថា "ការប៉ុនប៉ង" និង"ការសមគំនិតដើម្បីប្រព្រឹត្ត" អំពើប្រល័យពូជសាសន៍ គឺជា "ធាតុផ្សំមជ្ឈន្តិក" នៅក្នុងការចូលរួមប្រព្រឹត្តអំពើប្រល័យពូជសាសន៍ តាមរយៈសហកម្មឧក្រិដ្ឋកម្មរួម។ គ្មានជនណាម្នាក់អាចប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ដោយគ្មានការប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍នោះឡើយ។

២៥. ស្រដៀងគ្នានេះដែរ ធាតុផ្សំចាំបាច់ដើម្បីកំណត់អំពី "ការសមគំនិតដើម្បីប្រព្រឹត្ត" អំពើប្រល័យពូជសាសន៍គឺជាមជ្ឈដ្ឋានចំពោះការចូលរួមប្រព្រឹត្តតាមរយៈសហកម្មឧក្រិដ្ឋកម្មរួម[61]។ ដូចបានកំណត់យ៉ាងពិស្តារពីខាងលើគេអនុញ្ញាតឱ្យអនុវត្តបាន ចំពោះការកំណត់បទចោទផ្សេងចំពោះឈុតនៃអង្គហេតុដូចគ្នា ហើយក្នុងករណីណាក៏ដោយ គេបើកចំហរឱ្យអង្គជំនុំជម្រះសាលាដំបូងផ្លាស់ប្តូរការកំណត់បទចោទទៅនឹងឈុតនៃអង្គហេតុនានា។ ដូចដែល "ការប៉ុនប៉ង" និង "ការសមគំនិតដើម្បីប្រព្រឹត្ត" គឺជាបទចោទប្រកាន់ទាបជាងធាតុផ្សំនានា គឺជាធាតុផ្សំមជ្ឈន្តិកចំពោះបទចោទអំពីការចូលរួមប្រព្រឹត្តតាមរយៈសហកម្មឧក្រិដ្ឋកម្មរួម។ គេគ្មានបុរេវិនិច្ឆ័យចំពោះជនជាប់ចោទទេ បើសិនសហព្រះរាជអាជ្ញានឹងត្រូវយកចំណុចនេះមកតវ៉ាតាមរបៀបផ្លាស់គ្នាក្នុង

57 រដ្ឋអាជ្ញា ទល់នឹង Krstic, ដូចខាងលើ កំណត់សំគាល់៤៩, ត្រង់កថាខ័ណ្ឌទី១៣២ ។

58 រដ្ឋអាជ្ញា ទល់នឹង Krstic, ដូចខាងលើ កំណត់សំគាល់៤៩, ត្រង់កថាខ័ណ្ឌទី១០៤ ។

59 ញត្តិស្នើសុំលុបចោល, កថាខ័ណ្ឌទី២៦, ការដកស្រង់ ចេញពីដីកាដំណោះស្រាយ, កថាខ័ណ្ឌទី១៥២៧ ។

60 ញត្តិស្នើសុំលុបចោល, កថាខ័ណ្ឌទី១០ ។

61 Prosecutor ទល់នឹង *Milutinović*, *Šainović*, និង *Ojdanić*, ដូចខាងលើ កំណត់សំគាល់៤៥, កថាខ័ណ្ឌទី២៣ ។

ពេលសវនាការជំនុំជម្រះ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងមិនគួរកែប្រែដីកាដំណោះស្រាយដោយសារចំណុចនេះទេ។

## VI. ការធ្វើទុក្ខបុកម្នេញ

២៦. មេធាវីការពារក្តីតវ៉ាថា ដីកាដំណោះស្រាយមិនបានបញ្ជាក់ពីធាតុផ្សំមានលក្ខណៈរើសអើងចំពោះបទចោទនៃការធ្វើទុក្ខបុកម្នេញ ឲ្យដល់កំរិតនៃភាពជាក់លាក់គ្រប់គ្រាន់ទេ។ មេធាវីការពារក្តីនិយាយថា ដីកាដំណោះស្រាយមិនបានបញ្ជាក់ថាតើ "ប្រជាជនថ្មី" ត្រូវបានគេប្រព្រឹត្តមកលើ ខុសគ្នាដូចម្តេចខ្លះហើយខ្មាំង "ពិតប្រាកដ" ឬអ្នក "ដែលគេមើលថា" ជាខ្មាំង ត្រូវបានគេប្រព្រឹត្តមកលើមួយណាឃោរឃៅជាងមួយណាឡើយ។ ជាថ្មីម្តងទៀត ការអះអាងនេះមិនត្រឹមត្រូវទេ។ ដើម្បីជាឧទាហរណ៍ ការពិនិត្យឡើងវិញមួយត្រង់ជំពូក "សហករណ៍ និងការដ្ឋាន និងសហករណ៍" ទៅលើការរកឃើញអង្គហេតុ នៅក្នុងដីកាដំណោះស្រាយ បង្ហាញឲ្យឃើញអំពីអង្គធាតុពិស្តារនៃការប្រព្រឹត្តខុសៗគ្នាជាច្រើនទៅលើប្រជាជនថ្មី[62] និងខ្មាំងរបស់ បកក[63] ហេតុដូច្នោះហើយវាគឺជាការបញ្ជាក់អះអាងពីធាតុផ្សំដែលមានលក្ខណៈរើសអើងចំពោះឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ។

២៧. ទាក់ទិននឹងបំណងឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាឬជាតិពន្ធុ[64] ដីកាដំណោះស្រាយបានកំណត់ពី "បរិបទនៃការវាយប្រហារ" និង"កាលៈទេស"ពាក់ព័ន្ធដែលបានលើកយោង

---

62 ប្រជាជនថ្មី: (សហករណ៍ត្រាំកក់: កង្វះសិទ្ធិនយោបាយ, កថាខ័ណ្ឌទី៣០៥-០៦; បានចង្អុលបង្ហាញជាពិសេសដើម្បីកំណត់លើការធ្វើចំណាត់ថ្នាក់ការងារ និងសិទ្ធិ, កថាខ័ណ្ឌទី៣០៦; ការជម្លៀសពីលំនៅដ្ឋាន, កថាខ័ណ្ឌទី៣១០; បញ្ហាបទពិសោធន៍ខាងសុខភាព, កថាខ័ណ្ឌ៣១៣; បានចាប់ខ្លួន និងយកទៅបាត់, កថាខ័ណ្ឌទី៣១៩) (ការដ្ឋានត្រពាំងថ្ម: បានផ្តល់ចំនួនកំណត់សម្រាប់ការងារច្រើនជាង, កថាខ័ណ្ឌទី៣៤៣; ទទួលរងការឈឺចាប់ពីការផ្តន្ទាទោសដ៏អយុត្តិធម៌, កថាខ័ណ្ឌទី៣៤៣; បានចាប់ខ្លួន និងសម្លាប់ចោលពេលណាគេបានដឹង, កថាខ័ណ្ឌទី៣៤៣; បានចាប់ខ្លួនដើម្បី "ធ្វើការអប់រំកែប្រែឡើងវិញ", កថាខ័ណ្ឌទី៣៤៦; បានបាត់ខ្លួន, កថាខ័ណ្ឌទី៣៤៦; បានចាប់ខ្លួនទោះបីធ្វើបានសម្រេចការងារតាមចំនួនកំណត់ក៏ដោយ, កថាខ័ណ្ឌទី៣៤៦; បានចាប់ខ្លួន និងនាំទៅទីកន្លែងសម្លាប់ពេលណាគេបានកំណត់រួច, កថាខ័ណ្ឌទី៣៤៦) (ការដ្ឋានតំបន់១មករា: អាហារមិនគ្រប់គ្រាន់, កថាខ័ណ្ឌទី៣៦០; សម្លៀកបំពាក់ និងផ្ទះសម្បែងដ៏លំបាក, កថាខ័ណ្ឌទី៣៦០; ដកហូតមុខតំណែងជាក់លាក់មួយចំនួន, កថាខ័ណ្ឌទី៣៦០; បានបាត់ខ្លួន, កថាខ័ណ្ឌទី៣៦៦; បានសម្លាប់ចោល, កថាខ័ណ្ឌទី៣៦៦ ។

63 ខ្មាំងរបស់ បកក: (សហករណ៍ត្រាំកក់: ដាក់ចំណុចដៅសម្រាប់ការបោសសម្អាត, កថាខ័ណ្ឌទី៣០៩; បានកំណត់បង្ហាញដើម្បីចាប់ខ្លួន និងការអប់រំកែប្រែឡើងវិញ, កថាខ័ណ្ឌទី៣១៥; បានបញ្ជូនទៅមន្ទីរសន្តិសុខក្រាំង តាចាន់; បានបាត់ខ្លួន, កថាខ័ណ្ឌទី៣១៨; បានចាប់ខ្លួន និងនាំយកទៅបាត់, កថាខ័ណ្ឌទី៣១៩) (ការដ្ឋានតំបន់១មករា: បានបាត់ខ្លួន, កថាខ័ណ្ឌទី៣៦៦; បានសម្លាប់ចោល, កថាខ័ណ្ឌទី៣៦៦) (ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង: បានបោសសម្អាត, កថាខ័ណ្ឌទី៣៨៧; បានលត់ដំ, កថាខ័ណ្ឌទី៣៨៧-៨៩; បានលុបបំបាត់, កថាខ័ណ្ឌទី៣៨៧; បានចាប់ខ្លួន, កថាខ័ណ្ឌទី៣៨៧; បានកែប្រែ, កថាខ័ណ្ឌទី៣៨៩; បានបង្ខំឲ្យធ្វើការទាំងថ្ងៃទាំងយប់ ៧ ថ្ងៃ ក្នុងមួយអាទិត្យ, កថាខ័ណ្ឌទី៣៨៩-៩០; បានបញ្ជូនទៅ ស-២១, កថាខ័ណ្ឌទី៣៨៩; បានទទួលរងនូវការឈឺចាប់ពីលក្ខខណ្ឌការងារដ៏គ្រោះថ្នាក់, កថាខ័ណ្ឌទី៣៨៩; បានផ្តល់របបហូបចុកមិនគ្រប់គ្រាន់, កថាខ័ណ្ឌទី៣៩២; បានស្លាប់ដោយសារការអត់បាយ, ជម្ងឺ ការងារហួសកម្លាំង និងនឿយហត់, កថាខ័ណ្ឌទី៣៩២; បានបាត់ខ្លួន, ព្រាត់ប្រាស់ និងសម្លាប់ចោល, កថាខ័ណ្ឌទី៣៩៥-៩៨) (ការដ្ឋានព្រៃ ស: បានទទួលរងនូវការឈឺចាប់ពីការលត់ដំដ៏ឃោរឃៅ, កថាខ័ណ្ឌទី៤០៥; បានបង្ខំឲ្យធ្វើការដើម្បីធ្វើការអប់រំកែប្រែឡើងវិញ, កថាខ័ណ្ឌទី៤០៦; បានទទួលរងនូវការឈឺចាប់ពីលក្ខខណ្ឌការងារដ៏ឃោរឃៅ, កថាខ័ណ្ឌទី៤០៦) ។

ជាការផ្ទុះបញ្ជាំងឱ្យឃើញពីចេតនាចាំបាច់ នៅក្នុងកថាខ័ណ្ឌទាំងបួនមុនដល់ចំណុចនៃការដកស្រង់ដែលមេធាវីការពារក្តីបានជ្រើសយក[65]។ ដូចបានពន្យល់ពីខាងលើគេបានទទួលយកយ៉ាងឥតខ្ចោះដើម្បីកំណត់អំពីចេតនានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយផ្អែកទៅលើមូលដ្ឋាននៃការយល់ឃើញប្រកបដោយហេតុផល។

## VII. ការនិរទេស

២៨. មេធាវីការពារក្តីតវ៉ាថា សេចក្តីយោងទាំងឡាយអំពីការធ្វើនិរទេសជនជាតិភាគតិចវៀតណាមពីខេត្តព្រៃវែង ស្វាយរៀង និងសហករណ៍ត្រាំកក់ ធ្វើឱ្យដីកាដំណោះស្រាយមានវិការៈដោយសារថាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម មិនមានចែងពីអង្គហេតុនានាគាំទ្រចំពោះការសន្និដ្ឋានដូច្នេះទេ[66]។ ពួកគេតវ៉ាថា ការណ៍នេះនាំឱ្យសហចៅក្រមស៊ើបអង្កេតបំពានលើវិធាន៥៥.២ ហើយជាលទ្ធផល "ក.ស.ច.ស គ្មានយុត្តាធិការដើម្បីស៊ើបសួរអំពីការនិរទេសដូចដែលបានចោទប្រកាន់នេះទេ..."។

២៩. គេសន្និដ្ឋានថា គេមានមូលដ្ឋានគ្រប់គ្រាន់មួយនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតបើកការស៊ើបសួរទៅលើការនិរទេស[67] គេក៏មានកំណត់ផងដែរអំពីអង្គហេតុនានាដែលថា "... ប្រជាជនរាប់ម៉ឺននាក់ដែលកំពុងរស់នៅភូមិភាគបូព៌ា ..." ត្រូវបាន"បង្ខំឱ្យផ្លាស់ទីលំនៅ"[68] និងថាប្រជាជនទាំងនេះគឺរាប់បញ្ចូលទាំងប្រជាជនមក ពីព្រៃវែង និងស្វាយរៀង[69]។ ជាងនេះទៀត សហព្រះរាជអាជ្ញាបានចោទយ៉ាងជាក់លាក់លើគោលនយោបាយនៃការដាក់ោគោលដៅទៅលើជនជាតិវៀតណាម[70]។ ជាលទ្ធផល គេមានវិសាលភាពនៃអង្គហេតុគ្រប់គ្រាន់ដែលបានចោទប្រកាន់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរសម្រាប់សហចៅ ក្រមស៊ើបអង្កេតបង្វិលត្រឡប់មកវិញនូវលទ្ធផលរកឃើញមួយដែលថាជនជាតិវៀតណាម ក្នុង ចំនួនដ៏ច្រើនត្រូវបានគេនិរទេស។

៣០. ក្នុងពេលជាមួយគ្នានេះដែរ ពាក្យបណ្តឹងនេះមិនអាចទទួលយកបានទេ ។ ដោយហេតុថា ដីកាដំណោះស្រាយពេលនេះបានចូលជាស្ថាពរហើយ យុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងគ្មានការប៉ះពាល់ទេតាមរយៈពាក្យបណ្តឹងនេះ បើតាមស្មារតីនៃវិធាន៧៦.៧៖

---

64 ញត្តិស្នើសុំលុបចោល, កថាខ័ណ្ឌទី១៤ និង១៥ ។

65 ដីកាដំណោះស្រាយ, កថាខ័ណ្ឌទី១៤១៩ ដល់ ១៤២២ ។

66 ញត្តិស្នើសុំលុបចោល, កថាខ័ណ្ឌទី១១ ។

67 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខ័ណ្ឌទី១២២.គ ។

68 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខ័ណ្ឌទី៤២ ។

69 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខ័ណ្ឌទី៤២ ។

70 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខ័ណ្ឌទី៦៩ ។

"លើកលែងតែជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវតែកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ។ គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះ អាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ" ។

៣១. ជាងនេះទៀត គ្មានការខូចខាតផលប្រយោជន៍ត្រូវបានបង្កឡើងចំពោះជនជាប់ចោទ ដែលកើតចេញពីសកម្មភាពរបស់សហចៅក្រមស៊ើបអង្កេតទេ ។ ជនជាប់ចោទបានទទួលការជូនដំណឹងទាន់ពេលវេលា និងយ៉ាងពិស្តារអំពីបទចោទទាំងនេះ តាមស្មារតីនៃការដាក់បញ្ចូលនៅក្នុងដីកាដំណោះស្រាយ ដោយអនុលោមទៅតាមសិទ្ធិរបស់គាត់ដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)[71]។ អាស្រ័យហេតុនេះ គឺមិនអនុញ្ញាតឱ្យគាត់តវ៉ាចំពោះ កំហុសដូចដែលបានពោលទាំងនេះទេ[72] ។

## VII. សហកម្មឧក្រិដ្ឋកម្មរួម

៣២. ការព្យាយាមដើម្បីដកចេញរាល់សេចក្តីយោងទាំងអស់នៃសហកម្មឧក្រិដ្ឋកម្មរួម ពីដីកាដំណោះស្រាយ មេធាវីការពារក្តីបង្ហាញខុសកាន់តែច្រើនអំពីអង្គហេតុពិតដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលគាំទ្រចំពោះអត្ថិភាពនៃសហកម្មឧក្រិដ្ឋកម្មរួម។ មេធាវីការពារក្តីបានទាមទារថា ដីកាដំណោះស្រាយនិយាយថា "ការសន្និដ្ឋាននៅក្នុងដីកាដំណោះស្រាយដែលថា JCE អាចកើតមានឡើងនៅពេលដែលឧក្រិដ្ឋកម្មគ្រាន់តែជាលទ្ធផលដែលបណ្តាលមកពីគោលនយោបាយមិនមានលក្ខណៈឧក្រិដ្ឋប្រើដើម្បីអនុវត្តផែនការមិនមានលក្ខណៈឧក្រិដ្ឋ"[73]។ គ្មានកន្លែងណាមួយនៅក្នុងដីកាដំណោះស្រាយបាននិយាយថា គោលបំណងរួមឬគោលនយោបាយដែលបានអនុវត្តទាំងប៉ុន្មានដែលអនុលោមតាមសហកម្មឧក្រិដ្ឋកម្មរួម"មិនមានលក្ខណៈឧក្រិដ្ឋ"នោះទេ។ តាមពិត ដីកាដំណោះស្រាយនៅក្នុងកថាខ័ណ្ឌដែលបានដកស្រង់ដោយមេធាវីការពារក្តី និយាយថា"... គោលបំណងរួមនេះពុំមានលក្ខណៈឧក្រិដ្ឋទាំងស្រុងទេ..."[74]។ ការជាប់ទាក់ទងជាធម្មតាមួយនៃអត្ថបទនេះគឺថា គោលបំណងនេះយ៉ាងហោចណាស់មានលក្ខណៈឧក្រិដ្ឋមួយផ្នែក ជាជាង "មិនមានលក្ខណៈឧក្រិដ្ឋ"។

---

71 មាត្រា១៤.៣.ក នៃអនុសញ្ញា ICCPR ។

72 វិធាន៤៨ នៃវិធានផ្ទៃក្នុង ។

73 ញត្តិស្នើសុំលុបចោល, កថាខ័ណ្ឌទី២៣ ។

74 ជាឧទាហរណ៍, សូមអាន ដីកាដំណោះស្រាយ, កថាខ័ណ្ឌទី១៥២៤-១៥២៥, ដូចបានដកស្រង់នៅក្នុងញត្តិស្នើសុំ, កថាខ័ណ្ឌទី២១ ។

៣៣. ស្រដៀងគ្នានេះដែរ គ្មានអ្វីដើម្បីនឹងចង្អុលបង្ហាញភស្តុតាងអំពីការតវ៉ាទាមទារដែលថា ដីកាដំណោះស្រាយរៀបរាប់អំពីមានគោលនយោបាយចំនួនប្រាំដែលបានអនុវត្តដោយ បកក ថា "មិនមែនជាឧក្រិដ្ឋកម្ម"។ តាមពិត ដីកាដំណោះស្រាយបានបញ្ជាក់ច្បាស់ហើយថា គោលនយោបាយទាំងនេះតម្រូវឱ្យមានការអនុវត្តនូវឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់។ ឧទាហរណ៍ដូចជា: គោលនយោបាយស្តីពី "ការបង្កើត និងកិច្ចប្រតិបត្តិការនៃសហករណ៍ និងការដ្ឋានការងារនានា[75]"។ ដែលចាំបាច់តម្រូវឱ្យមានការអនុវត្ត ក្នុងចំណោមឧក្រិដ្ឋកម្មដទៃទៀតជាច្រើន នូវ "ការធ្វើឱ្យទៅជាទាសករ" ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយ[76]។ "ការអប់រំកែប្រែសមាសភាពមិនល្អ និងការសម្លាប់ខ្មាំង"[77] (ការសង្កត់ន័យបន្ថែមដោយអក្សរទ្រេត) ដែលតម្រូវឱ្យផ្នែកជារួមទាំងស្រុងនៃការអនុវត្តនូវបទឧក្រិដ្ឋនានា ក្នុងចំណោមឧក្រិដ្ឋកម្មដទៃទៀតច្រើន ដែលរួមមានការធ្វើមនុស្សឃាត[78], ការសម្លាប់រង្គាល[79], ការដាក់ក្នុងមន្ទីរឃុំឃាំង[80], និងការធ្វើទារុណកម្ម[81] ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយ ។ ចំណែកឯ "ការផ្តោតមុខសញ្ញាទៅលើក្រុមជាក់លាក់[82]"វិញគឺជាការបន្តមត៌កក្នុងចំណោមឧក្រិដ្ឋកម្មដទៃទៀតជាច្រើន រួមមានការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុខាងនយោបាយ[83], ពូជសាសន៍[84], ឬសាសនា[85] ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយនិងការសម្លាប់ដោយចេតនា[86] និងការនិរទេស[87] និងបង្ខាំងប្រជាជនស៊ីវិលដោយខុសច្បាប់[88]ដែលជាអំពើបំពារបំពានធ្ងន់ធ្ងរនានាទៅលើអនុសញ្ញានៃទីក្រុងហ្សឺណែវ។

៣៤. មានការបញ្ជាក់យ៉ាងច្បាស់រួចហើយនៅក្នុងអត្ថបទសំខាន់ជាសារវ័ន្តនៃដីកាដំណោះស្រាយចំនួនជាង៤០១ទំព័រថា គោលនយោបាយទាំងនេះគឺជាមត៌កនៃឧក្រិដ្ឋកម្ម។ ប្រការដែលថា ពួកគេប្រហែលអាចមានគោលដៅដែលមិនមែនជាឧក្រិដ្ឋដែរ នោះគឺមិនមានការជាប់ទាក់ទងគ្នាទេ ហើយគឺ

75 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១៥៧។

76 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ កថាខណ្ឌទី១៣៨១-១៣៨៦, ជាពិសេស កថាខណ្ឌទី១៣៨៣។

77 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១៥៧។

78 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ កថាខណ្ឌទី១៣៧៣-១៣៨០, ជាពិសេស កថាខណ្ឌទី១៣៧៧។

79 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១៣៩០។

80 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១៤០៧។

81 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១៤២៥។

82 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១៥៧។

83 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១៤១៧។

84 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១៤២២។

85 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១៤១៩។

86 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១៤៩១-១៤៩៧។

87 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១៥១៥-១៥១៧។

88 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១៥១៨-១៥២០។

00652164



ជាការរៀចវេរដែលលើកស្នើថា ក្នុងផែនការរួមក្តី ឬក្នុងគោលនយោបាយនានារបស់ បកក ក្តី នៅកន្លែងណាក៏ដោយក្នុងដីកាដំណោះស្រាយគឺត្រូវបានកំណត់ថា "មិនមែនជាឧក្រិដ្ឋកម្ម"ទេ។

៣៥. មេធាវីការពារក្តីចោទថា "អង្គហេតុ និងកាលៈទេសៈនានា...ដែលបានលើកឡើងទាក់ទង ទៅនឹងការចូលរួម និងការរួមចំណែករបស់លោក អៀង សារី នៅក្នុងផែនការរួម គឺសុទ្ធតែមិនគាំទ្រចំពោះការទាញសេចក្តីសន្និដ្ឋានដែលថា គាត់បានសំដែងឱ្យឃើញពីចេតនាចូលរួមចំណែកនៅក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ[89]"។ ជាថ្មីម្តងទៀត ការចោទរបស់មេធាវីការពារក្តីគឺស្ថិតក្នុងជំហរដែលមានភាពផ្ទុយគ្នាដ៏ស្រួចស្រាវទៅនឹងអង្គហេតុនានាដូចដែលមាននៅក្នុងដីកាដំណោះស្រាយ។ឧក្រិដ្ឋភាពនៃផែនការរួម និងគោលនយោបាយរួមគឺត្រូវបានលើកឡើងរួចហើយ។ ការដែលថា អៀង សារី គាត់បានសំដែងឱ្យឃើញពីចេតនាចូលរួមចំណែកនៅក្នុងការប្រព្រឹត្តបទឧក្រិដ្ឋអាចបង្ហាញឱ្យឃើញភស្តុតាង ឬអាចទាញសេចក្តីសន្និដ្ឋានបានមកពី៖ (១) ការយល់ព្រមដោយស្ម័គ្រចិត្តរបស់គាត់ និងការមានឆន្ទៈចូលរួមនៅក្នុងមុខតំណែង និងតួនាទីជាន់ខ្ពស់ផ្សេងៗដែលអាចផ្តល់លទ្ធភាពឱ្យគាត់អាចចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមបាន[90]។ (២) សកម្មភាពរបស់គាត់ក្នុងការគិតធ្វើឱ្យឧក្រិដ្ឋកម្មនានាកើតមានឡើងដោយរួមគ្នាជាមួយសហចារីទាំងឡាយរបស់គាត់[91]និងការជម្រុញការប្រព្រឹត្តឱ្យបានបន្តទៅមុខទៀតដោយ ក្នុងចំណោមសកម្មភាពដទៃទៀតជាច្រើន រួមមាន ការជួបប្រជុំជាមួយកម្មាភិបាល និងការចេញសេចក្តីណែនាំផ្សេងៗដល់ពួកកម្មាភិបាល បកក ថ្នាក់ក្រោមទាំងនោះ[92]ការចុះទៅពិនិត្យមើលទីកន្លែងឧក្រិដ្ឋកម្ម[93] និងការចូលរួមចំណែកដោយខ្លួនគាត់ផ្ទាល់នៅក្នុងឧក្រិដ្ឋកម្មនានា[94]។ (៣) សុន្ទរកថា និងសេចក្តីថ្លែងការណ៍នានារបស់គាត់, ការលើកទឹកចិត្តឱ្យប្រព្រឹត្តបទឧក្រិដ្ឋផ្សេងៗ[95],ហើយនឹងការការពារគោលនយោបាយរបស់ បកក នៅមុនពេល និងនៅក្នុងអម្លុងពេលដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរ[96]។ (៤) ការឃោសនានានារបស់ បកក ដែលគាត់បានចូលរួមចំណែកក្នុងនោះ និងបានយល់ព្រម ហើយបានគាំទ្រថែមទៀត[97] (៥) សេចក្តីថ្លែងការណ៍នានារបស់គាត់នៅក្នុងពេលធ្វើការបំពាក់បំប៉នសតិអារម្មណ៍នយោបាយ និងលត់ដំគោលជំហរដល់កម្មាភិបាល បកក[98]។ (៦) សកម្មភាពទាំងឡាយ, សំណេរ និង

---

89 ញត្តិស្នើសុំលុបចោលនូវផ្នែកខ្លះ, កថាខណ្ឌទី២៤។

90 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១០០១, ១០០៨។

91 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១០២២, ១០២៤, ១០២៩, ១០៤៩។

92 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១០១១, ១០៥០។

93 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១០៤៥។

94 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១០៤៩, ១០៦២, ១០៧២, ១០៧៣,១០៧៤។

95 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១១០៨។

96 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១០២០, ១០២១, ១០២៣, ១០៣០-១០៤២, ១០៥២-១០៦០, ១១១៧, ១១២១។

97 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១០១៥, ១០២៤, ១១១៩។

98 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១០៣០, ១០៩៤, ១៥៣៤។

សេចក្តីថ្លែងការណ៍នានារបស់គាត់[99] ដែលក្នុងនោះរួមទាំងសកម្មភាព សំណេរ និងសេចក្តីថ្លែងការណ៍ទាំងឡាយដែលគាត់ខំប្រឹងទប់ស្កាត់កុំឲ្យរកឃើញនូវឧក្រិដ្ឋកម្មផ្សេងៗទៀត[100]។

៣៦. ការពោលអះអាងរបស់មេធាវីការពារក្តីដែលថា ករណីបើសិនជាការរកឃើញនានាទាក់ទងនឹងការចូលរួម និងចេតនារបស់ជនជាប់ចោទពាក់ព័ន្ធទៅនឹងសហកម្មឧក្រិដ្ឋកម្មរួមត្រូវបានឈានដល់សំរេចគោលដៅតាមវិធីទាញសេចក្តីសន្និដ្ឋាន ការទាញសេចក្តីសន្និដ្ឋានបែបនេះតោងតែជាការទាញសេចក្តីសន្និដ្ឋានតែមួយប៉ុណ្ណោះដែលសមហេតុសមផលដែលអាចឲ្យទាញយកមកបាន[101] ចំណុចនេះត្រូវបានលើកឡើងរួចហើយ។ នេះគឺជាលក្ខខណ្ឌដែលតម្រូវឲ្យមានការបង្ហាញភស្តុតាងអំពីការទាញសេចក្តីសន្និដ្ឋានផ្សេងៗឲ្យបានស្របទៅតាមបទដ្ឋានចាំបាច់ដើម្បីឲ្យជនជាប់ចោទត្រូវបានកាត់ក្តីឲ្យមានទោសក្នុងសវនាការ។ តាមគោលបំណងនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺវាគ្រប់គ្រាន់ដើម្បីអាចឲ្យទាញសេចក្តីសន្និដ្ឋានដ៏សមហេតុសមផលពីអង្គហេតុនិងពីកាលៈទេសៈនានាស្តីពីការចូលរួមនិងអំពីចេតនារបស់ អៀង សារី និងរបស់ចុងចោទដទៃទៀតបានហើយ។

## IX. ទម្រង់នៃការទទួលខុសត្រូវផ្សេងៗទៀត

៣៧. មេធាវីការពារក្តីបានចោទថា ដីកាដំណោះស្រាយខកខានមិនបានចែងពី "ការកំណត់បទចោទគ្រប់គ្រាន់ផ្អែកលើអង្គហេតុ ដើម្បីគាំទ្រចំពោះការទទួលខុសត្រូវ" ក្នុងការរៀបចំផែនការ, ការញុះញង់, ការជួយ និងជម្រុញ, និងការបញ្ជាឡើយ[102]។ ផ្ទុយពីការពោលអះអាងនេះ ដីកាដំណោះស្រាយបានរៀបរាប់ដោយលំអិតអំពីអង្គហេតុនានាដែលគាំទ្រចំពោះរាល់ទម្រង់នៃការទទួលខុសត្រូវទាំងនេះ។ នៅក្នុងផ្នែកស្តីពី "តួនាទីរបស់ជនជាប់ចោទ" ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានផ្តល់នូវសេចក្តីរៀបរាប់លំអិត និងប្រការជាក់លាក់យ៉ាងច្បាស់លាស់ដែលមានចំនួន៣៣ទំព័រស្តីពីមុខតំណែង, តួនាទី, និងការចូលរួមរបស់គាត់នៅក្នុងគ្រប់បទឧក្រិដ្ឋទាំងអស់ដែលបានចោទប្រកាន់[103]។ តាមវិធីអធិប្បាយពន្យល់យ៉ាងច្បាស់ ដោយយោងទៅលើផ្នែកស្តីពី "តួនាទីរបស់ជនជាប់ចោទ" នៅក្នុងដីកាដំណោះស្រាយបានបង្ហាញឲ្យឃើញថាការចោទផ្សេងៗទាក់ទងទៅនឹងអង្គហេតុដែលពាក់ព័ន្ធនឹងគ្រប់ទម្រង់ទាំងអស់នៃការទទួលខុសត្រូវ គឺសុទ្ធតែត្រូវបានធ្វើឡើងដោយមានការបញ្ជាក់ពីចំណុចជាក់លាក់យ៉ាងចំៗ។

---

99 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី ១០៣០-១០៤២។

100 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១១១០-១១១៣។

101 ញត្តិស្នើសុំលុបចោលនូវផ្នែកខ្លះ, កថាខណ្ឌទី២៤។

102 ញត្តិស្នើសុំលុបចោលនូវផ្នែកខ្លះ, កថាខណ្ឌទី២៨។

103 ញត្តិស្នើសុំ, ទំព័រ២៥០-២៨៤។

៣៨. ការរៀបចំផែនការ៖ ដីកាដំណោះស្រាយបាននិយាយថា ក្នុងនាមជាសមាជិកមួយរូបនៃគណៈកម្មាធិការអចិន្ត្រៃយ៍តើ អៀង សារី[104] បានកាន់កាប់សិទ្ធិអំណាចដើម្បីចូលរួមចំណែកនៅក្នុងការបង្កើតគោលនយោបាយរបស់ បកក[105] និងបានប្រើប្រាស់នូវសិទ្ធិអំណាចនោះដើម្បីចូលរួមនៅក្នុងការរៀបចំគំរោងនៃឧក្រិដ្ឋកម្មទាំងនោះយ៉ាងដូចម្តេចខ្លះ?[106]។ គាត់បានចូលរួមចំណែកនៅក្នុងការពិភាក្សា និងនៅក្នុងការធ្វើសេចក្តីសំរេចនានាដែលនាំឲ្យមានការបង្កើតឡើងនូវគោលដៅដ៏ឧក្រិដ្ឋនានា និងការបង្កើតជាយន្តការផ្សេងៗសម្រាប់អនុវត្តនូវសេចក្តីណែនាំដ៏ឧក្រិដ្ឋនានារបស់មជ្ឈិមបក្ស[107] លើសពីនេះ ដីកាដំណោះស្រាយបានធ្វើការពន្យល់អំពីថាតើ អៀង សារី ក្នុងនាមជាប្រធាននៃក្រសួងការបរទេសបានចូលរួមចំណែកនៅក្នុងការរៀបចំផែនការនៃការចាប់ខ្លួនកម្មាភិបាលក្រសួងការបរទេស[108] និងកោះហៅឲ្យពួកបញ្ញាវ័ន្ត ឯកអគ្គរាជទូត និងបុគ្គលិកការទូតនានាឲ្យវិលត្រឡប់មកវិញ ដែលបន្ទាប់មកទៀតពួកអ្នកទាំងនោះក្លាយទៅជាជនរងគ្រោះដោយសារឧក្រិដ្ឋកម្មផ្សេងៗបែបដូចម្តេចខ្លះ?[109]។

៣៩. ការញុះញង់៖ ដីកាដំណោះស្រាយបានពន្យល់អំពីថាតើ អៀង សារី បានលើកទឹកចិត្ត និងជំរុញពួកកម្មាភិបាលនានាឲ្យប្រព្រឹត្តបទឧក្រិដ្ឋនានាតាមរយៈអំពើទាំងឡាយដែលរួមមាន៖ ការដឹកនាំ និងធ្វើជាអធិបតីនៅក្នុង បកក វគ្គបំពាក់បំប៉នសតិអារម្មណ៍នយោបាយនានា[110] និងការរួមប្រជុំផ្សេងៗទៀតជាមួយកម្មាភិបាលក្រសួងការបរទេស និងបកក ដែលនៅក្នុងពេលនោះពួកអ្នកដែលទៅចូលរួមត្រូវបានគេជំរុញឲ្យប្រព្រឹត្តបទឧក្រិដ្ឋផ្សេងៗ[111]។ ហើយនឹងការចុះទៅពិនិត្យមើលតាមទីតាំងនៃឧក្រិដ្ឋកម្មនានា[112]។ ជាងនេះទៅទៀត ដីកាដំណោះស្រាយក៏បានលើកឡើងអំពីថាតើ អៀង សារី បានបង្កឲ្យមានការបោសសំអាត, ការចាប់ខ្លួន, ការធ្វើទារុណកម្ម និងការសម្លាប់កម្មាភិបាលនានានៃក្រសួងការបរទេស[113] ហើយបន្ថែមពីលើនេះ បានលើកទឹកចិត្តក្នុងការប្រព្រឹត្តបទឧក្រិដ្ឋនានាដោយការធ្វើយុត្តិកម្ម និងផ្តល់ការយល់ព្រមជាសាធារណៈទៅលើគោលនយោបាយដ៏ឧក្រិដ្ឋនានារបស់ បកក យ៉ាងដូចម្តេចខ្លះ?[114]។

---

104 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១០០១។

105 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី៤១, ៤៦, ១៧១, ១៨៤, ១០២៨, ១០៤៩។

106 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១០៦៦។

107 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១០០១, ១០២៩, ១០៧៣។

108 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១០៧២, ១០៧៣។

109 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១០៩៣, ១០៩៦, ១៤១៧, ១៥៣៥។

110 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១០៣០, ១០៩៤, ១៥៣៥។

111 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១០០៣, ១០១០, ១០២០, ១០៦១។

112 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១០៥៥។

113 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១០៨៦, ១០៨៧, ១០៨៨។

114 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១០២០, ១០២១, ១០២៣, ១០៣០-១០៤២, ១០៥២-១០៦០, ១១១៧, ១១២១។

00652167



៤០. ការបញ្ជា៖ ដីកាដំណោះស្រាយរៀបរាប់អំពីថាតើ អៀង សារី បានអនុវត្តសិទ្ធិអំណាចរបស់ខ្លួនទាំងតាមជាក់ស្តែង និងទាំងតាមផ្លូវច្បាប់ និងបានធ្វើសកម្មភាពដោយត្រូវរ៉ូវគ្នាជាមួយមេដឹកនាំជាន់ខ្ពស់នានាផ្សេងទៀតរបស់ បកក, បានបង្កើត និងចេញនូវបទបញ្ជា និងសារាចរណែនាំដល់កម្មាភិបាល បកក នានាដើម្បីឲ្យប្រព្រឹត្តបទឧក្រិដ្ឋនានាបែបដូចម្តេចខ្លះ?[115]។ ក្នុងនាមជាសមាជិករបស់មជ្ឈិមបក្ស គាត់បានចូលរួមនៅក្នុងការបញ្ជារួមទាំងនេះ និងបានទទួលនូវរបាយការណ៍នានាស្តីពីការអនុវត្តរបស់ពួកគេ[116]។

៤១. ការជួយ និងជំរុញ៖ ដីកាដំណោះស្រាយបានលើកឡើងអំពីអង្គហេតុជាក់ស្តែងដែលចាំបាច់សំរាប់បង្ហាញឲ្យឃើញថា អៀង សារី បានជួយ និងជំរុញនៅក្នុងការប្រព្រឹត្តបទឧក្រិដ្ឋនានា។ ដីកាដំណោះស្រាយ បានបង្ហាញឲ្យឃើញថា គាត់បានជួយនៅក្នុងការផ្តល់ជំនួយក្នុងការអនុវត្ត និងគាំទ្រដល់ឧក្រិដ្ឋកម្មនានា ដែលបានកើតឡើងនៅមន្ទីរស-២១ ដោយផ្តល់ការយល់ព្រមដល់ការចាប់ខ្លួន និងការបញ្ជូនកម្មាភិបាលក្រសួងការបរទេសមួយចំនួនទៅកាន់មន្ទីរសន្តិសុខនោះ[117] និងដោយលើកទឹកចិត្ត និងផ្តល់ការគាំទ្រខាងផ្លូវចិត្តដល់កម្មាភិបាលក្រសួងការបរទេសទាំងឡាយណាដែលបានចូលរួមនៅក្នុងការចាប់ខ្លួនទាំងនោះ[118]។ ស្រដៀងគ្នានេះ គាត់បានជួយ និងជំរុញឲ្យមានការប្រព្រឹត្តបទឧក្រិដ្ឋនានានៅមន្ទីរស-២១ ដោយការចូលរួមនៅក្នុងវិធីដំណើរការនៃអំពាវនាវឲ្យមន្ត្រីការទូត, បញ្ញវ័ន្ត, និងនិស្សិតនានាពីបរទេសឲ្យវិលត្រឡប់មកវិញ[119]។ គាត់ក៏បានលើកទឹកចិត្តផងដែរដល់ការប្រព្រឹត្តបទឧក្រិដ្ឋផ្សេងៗដែលបានកើតឡើងដែលជាផ្នែកនៅក្នុងគោលនយោបាយរបស់ បកក ក្នុងការធ្វើឲ្យទៅជាទាសករ, និងការធ្វើពលកម្មដោយបង្ខំ ដោយការចុះទៅពិនិត្យមើលការដ្ឋាននានា[120]និងដោយការថ្លែងសុន្ទរកថានិងការធ្វើសេចក្តីថ្លែងការណ៍ដែលផ្តល់ការយល់ព្រមទៅលើគោលនយោបាយទាំងនោះនៅក្នុងវេទិកាអន្តរជាតិនានាដូចជានៅក្នុងអង្គការសហប្រជាជាតិជាដើម[121]។

៤២. ក្រៅពីការចោទអំពីកង្វះខាតចំណុចជាក់លាក់ទាក់ទងទៅនឹងទម្រង់ផ្សេងៗនៃការទទួលខុសត្រូវជាបន្ថែមពីលើនេះ មេធាវីការពារក្តីបានជជែកតវ៉ាថា ការលើកសំអាងដែលជាជំនួសឲ្យចំណុចជាក់លាក់ទាំងនេះគឺមិនអាចអនុញ្ញាតឲ្យបានទេ។ ដូចដែលសហព្រះរាជអាជ្ញាបានពោលអះអាងរួចមកហើយថា ការចោទប្រកាន់ពីបទចោទដែលជាជំនួសឲ្យទម្រង់នៃការទទួលខុសត្រូវនានាគឺជា

115 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១០១១, ១០២២, ១០២៤, ១០២៩, ១០៤៩, ១០៥០។

116 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី៤៦, ៧២, ៥៧៥, ៨២៧, ៨៣៧, ១០២០, ១០៤៤, ១០៦៣។

117 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១០៧២ និង ១០៧៣។

118 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១៨០៧។

119 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១០៩៣, ១០៩៦, ១៤១៧, ១៥៣៤។

120 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១០៥៥។

121 សូមអានឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី១០៣៤, ១០៣៩, ១០៥៤។

00652168



ការអនុវត្តមួយដ៏សមស្របនិងដែលអាចឱ្យទទួលយកបាន នៅក្នុងបណ្តាតុលាការនានាក្នុងការដោះស្រាយលើករណីរឿងឧក្រិដ្ឋកម្មផ្សេងៗដែលមានវិសាលភាពស្រដៀងគ្នានេះ។

## X. ការទទួលខុសត្រូវរបស់មេបញ្ជាការ

៤៣. ជាចុងក្រោយ មេធាវីការពារក្តីបានជជែកតវ៉ាថា រាល់សេចក្តីយោងទាំងអស់ដូចជា ការទទួលខុសត្រូវរបស់ថ្នាក់លើ ឬការទទួលខុសត្រូវរបស់មេបញ្ជាការគួរតែបានលុបចេញពីក្នុងដីកាដំណោះស្រាយដោយសារធាតុផ្សំដែលតម្រូវឱ្យមាន គឺមិនត្រូវបានលើកឡើងជាចំណុចជាក់លាក់គ្រប់គ្រាន់នោះទេ។ ក្នុងការព្យាយាមដើម្បីបង្ហាញឱ្យឃើញច្បាស់ពីរឿងនេះ មេធាវីការពារក្តីទាំងនេះបានដកស្រង់សំដីដោយជ្រើសយកចោះៗពីកថាខណ្ឌទី១៥៥៩-១៥៦០ នៃដីកាដំណោះស្រាយដែលនិយាយថា "គ្រាន់តែនិយាយ "ថា "មានភស្តុតាងគ្រប់គ្រាន់តែប៉ុណ្ណោះ"[122]។ តាមពិតទៅនៅក្នុងដីកាដំណោះស្រាយបាននិយាយថា "...ដូចដែលមានចែងនៅក្នុងផ្នែកស្តីពី "តួនាទីរបស់ជនត្រូវចោទ" នៃដីកាដំណោះស្រាយនេះ មានភស្តុតាងគ្រប់គ្រាន់...[123]" នេះគឺជាមធ្យោបាយដ៏ឥតខ្ចោះដែលអាចឱ្យទទួលយកបានក្នុងការដែលយោងទៅលើអង្គហេតុជាក់ស្តែងដោយមិនបាច់និយាយដដែលៗឡើងវិញទាំងអស់ទាំងស្រុង៖ ដូចដែលបានរៀបរាប់ខាងលើ កថាខណ្ឌនីមួយៗតោងតែត្រូវបានចាត់ទុកថាស្ថិតនៅក្នុងបរិបទនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូល។

៤៤. ជាការជាក់ស្តែង អង្គហេតុជាក់ស្តែងនានាគឺវាគ្រប់គ្រាន់ដើម្បីបង្ហាញភស្តុតាងនីមួយៗនៃលក្ខខណ្ឌដែលតម្រូវឱ្យមានការទទួលខុសត្រូវរបស់ថ្នាក់លើដែលត្រូវបានធ្វើឱ្យមានលក្ខណៈជាក់លាក់នៅក្នុងផ្នែកស្តីពី"តួនាទីរបស់ជនត្រូវចោទ"និងនៅផ្នែកផ្សេងៗទៀតនៃដីកាដំណោះស្រាយ។មុខតំណែង របស់ អៀង សារី នៅក្នុង បកក នៅក្នុងចំណោមមុខតំណែងដទៃទៀតជាច្រើន រួមមានជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិមបក្ស និងគណៈកម្មាធិការអចិន្ត្រៃយ៍[124] និងជារដ្ឋមន្ត្រីក្រសួងការបរទេស[125]គឺមានន័យថាជាទំនាក់ទំនងរវាងថ្នាក់លើថ្នាក់ក្រោមបង្គាប់ដោយផ្ទាល់, ដោយប្រយោល, ឬតាមជាក់ស្តែង ដែលមានអត្ថិភាពរវាងរូបគាត់ហើយនឹងរាល់កម្មាភិបាល បកក ទាំងអស់ដែលបានចូលរួមដោយផ្ទាល់នៅក្នុងឧក្រិដ្ឋកម្មនានា។ ការត្រួតត្រាដ៏មានប្រសិទ្ធភាពរបស់គាត់ទៅលើពួកកម្មាភិបាលទាំងនោះគឺត្រូវបានបង្ហាញឱ្យឃើញតាមរយៈ៖ (១) សមត្ថភាពរបស់គាត់ ដែលជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងការចេញសារាចរ

---

122 ញត្តិស្នើសុំលុបចោលនូវផ្នែកខ្លះ, កថាខណ្ឌទី១៨។

123 ដីកាដំណោះស្រាយ, កថាខណ្ឌទី១៥៥៩។

124 ដីកាដំណោះស្រាយ, កថាខណ្ឌទី១០០១។

125 ដីកាដំណោះស្រាយ, កថាខណ្ឌទី១០០៨។

ណែនាំនានាដល់គ្រប់រាល់អង្គភាពទាំងអស់នៃ បកក នៅក្នុងកម្ពុជាប្រជាធិបតេយ្យ[126]។ (២) ការចូលរួមរបស់គាត់នៅក្នុងការធ្វើសេចក្ដីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ដើម្បីធ្វើការស៊ើបអង្កេត និង/ឬដាក់ទណ្ឌកម្មចំពោះកម្មាភិបាលជាន់ខ្ពស់ បកក ដែលជាប់សង្ស័យពីរឿងវិន័យឬពីភាពមិនស្មោះត្រង់[127] និង(៣) តួនាទីរបស់គាត់នៅក្នុងការផ្ដល់ការយល់ព្រមដោយខ្លួនគាត់ផ្ទាល់ចំពោះការបោសសំអាតនានានៅក្នុងរង្វង់ក្រសួងការបរទេស[128]។

៤៥. កម្មាភិបាលនានានៃ បកកដែលមាន អៀង សារី ជាអ្នកត្រួតត្រាពីលើដ៏មានប្រសិទ្ធភាពក្នុងនាមជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ គឺសុទ្ធតែជាចារីនៃឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។ ការប្រព្រឹត្តរបស់ពួកគេ គឺមានរៀបរាប់ដោយសេចក្ដីលំអិតបំផុតនៅក្នុងដីកាដំណោះស្រាយទាំងមូល[129]។ ការដឹងឮរបស់ អៀង សារី អំពីការប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ ត្រូវបានបង្ហាញភស្តុតាងថា គឺជាផលវិបាកមួយដែលបណ្ដាលមកពីមុខតំណែងរបស់គាត់នៅក្នុងគណៈកម្មាធិការមជ្ឈិមបក្ស។ ក្នុងនាមជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ គឺគាត់បានស្ថិតនៅត្រង់ចំណុចកណ្ដាលនៃប្រព័ន្ធមួយដែលមានការបញ្ជូនពត៌មានជាប្រចាំដែលមកពីតាមបណ្ដាផ្នែកនីមួយៗនៃឋានានុក្រមរដ្ឋបាលរបស់កម្ពុជាប្រជាធិបតេយ្យ[130]។ លើសពីនេះមានករណីជាច្រើនមានទូរលេខដែលក្នុងនោះមានព័ត៌មានទាក់ទងអំពីឧក្រិដ្ឋកម្មនានា ត្រូវបានគេចម្លងជូនដោយចំ ឈ្មោះ អៀង សារី ផ្ទាល់តែម្ដង[131]។ ជាចុងក្រោយគឺមិនមានអ្វីដែលបង្ហាញឲ្យឃើញថា អៀង សារី ដែលក្នុងនាមជាស្ថាបត្យករដើមអាទិ៍ម្នាក់នៃឧក្រិដ្ឋកម្មក្នុងចំណោមស្ថាប័ត្យករផ្សេងៗទៀតបានខំប្រឹងក្នុងការទប់ស្កាត់ចំពោះអ្នកក្រោមបង្គាប់ទាំងឡាយ របស់គាត់កុំឲ្យប្រព្រឹត្ត ឬដាក់ទណ្ឌកម្មពួកគេក្នុងការប្រព្រឹត្តនូវបទឧក្រិដ្ឋទាំងនេះនោះឡើយ។

៤៦. ហេតុដូចនេះ គឺមិនអាចនិយាយបានថាដីកាដំណោះស្រាយមានការខ្វះនូវចំណុចជាក់លាក់ដែលចាំបាច់សម្រាប់បង្ហាញភស្តុតាងអំពីការទទួលខុសខាងព្រហ្មទណ្ឌជាបុគ្គលតាមទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើបានឡើយ។

---

126 ដីកាដំណោះស្រាយ, កថាខណ្ឌទី៤១, ៤៣, ៤៦។

127 ដីកាដំណោះស្រាយ, កថាខណ្ឌទី៩៤៣, ១១៨៥។

128 ដីកាដំណោះស្រាយ, កថាខណ្ឌទី១០៧២, ១០៧៣។

129 សូមអាន ក្នុងចំណោមដីកាជាច្រើនទៀត ដីកាដំណោះស្រាយ, កថាខណ្ឌទី២៩៨, ៣០០, ៣៧៨, ៣៨៦, ៤៧៨, ៦៩៦, ៧៨៥, ៧៨៧,៨២៨ ។

130 ដីកាដំណោះស្រាយ, កថាខណ្ឌទី៤៦ និង៧២។

131 សូមអាន ឧទាហរណ៍ដូចជា ដីកាដំណោះស្រាយ, កថាខណ្ឌទី៥៧៥, ៨២៧, ៨៣៧, ១០២០, ១០៤៤, ១០៦៣។

## XI. ឧបាស្រ័យដែលបានស្នើសុំ

៤៧. ដោយយល់ឃើញចំពោះការទាញហេតុផលដូចដែលបានផ្តល់ជូនខាងលើនេះ សូមគោរពជូនសេចក្តីសន្និដ្ឋានថា ញត្តិស្នើសុំឲ្យលុបចោលផ្នែកខ្លះនេះគួរបានបដិសេធចោល ដោយសារមិនអាចឲ្យទទួលយកបាន ហើយជំនួសមកវិញក្នុងករណីណាក៏ដោយ គួរបានបដិសេធញត្តិនេះលើអង្គសេចក្តី៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |